ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ ១៦២ បទ.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌ និង នីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និង ការដកហូត លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និង មាត្រា២៩ និង បំពេញបន្ថែមមាត្រា២៩ ស្ទួន

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨១០/៤២៦៥១០
ទូរសារ (៨៥៥) ២៣-៧២៤០៦៩

នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- បានឃើញប្រកាសលេខ ១៦១ បទ.ប្រក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានទីមួយៗនៃនិយ័តករទូរគមនាគមន៍កម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌ និង នីតិវិធីនៃការផ្ដល់ ការកែប្រែ ការពន្យារ ការផ្ទេរ និង ការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ និង អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅកំណត់អំពី ៖

- លក្ខខណ្ឌ និង នីតិវិធីសម្រាប់ដាក់ពាក្យស្នើសុំ ផ្ដល់ កែប្រែ ពន្យារ ផ្ទេរ ឬ ដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ។
- ប្រតិបត្តិការដែលបានទទួលការអនុញ្ញាត សិទ្ធិ និង កាតព្វកិច្ចនៃអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ។
- យន្តការត្រួតពិនិត្យ និង វិធានការនានាចំពោះអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ។
- ការកែសម្រួល និង/ឬ បំពេញបន្ថែមឱ្យស្របតាមប្រកាសនេះនូវរាល់ខ្លឹមសារ និង លក្ខខណ្ឌនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ដែលបានផ្ដល់មុនច្បាប់ស្ដីពីទូរគមនាគមន៍ និង បទប្បញ្ញត្តិនានាចូលជាធរមាន ។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិការទូរគមនាគមន៍ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រកាសនេះ មិនអនុវត្តចំពោះផ្នែកមាតិកាទាំងឡាយ រួមមាន ស៊ីញ៉ាល់ អត្ថបទ រូបភាព សំឡេង ឬ មធ្យោបាយវែយច្ឆាតដទៃទៀតពាក់ព័ន្ធនឹងការផ្តល់សេវាទូរគមនាគមន៍ដែលពុំស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីទូរគមនាគមន៍ និង បទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតទេ ។

**ប្រការ ៤.-**

និយមន័យនៃពាក្យបច្ចេកទេសទាំងឡាយ បានកំណត់ក្នុងសទ្ទានុក្រមភ្ជាប់ជាឧបសម្ព័ន្ធទី ១ នៃប្រកាសនេះ ។

## ជំពូកទី ២
## ការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍

### ផ្នែកទី ១
### លក្ខខណ្ឌទូទៅ

**ប្រការ ៥.-**

ប្រកាសនេះ កំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការដាក់ពាក្យស្នើសុំ និង គោលការណ៍រួមនៃការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍, លក្ខខណ្ឌ និង នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ព្រមទាំងលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ សម្រាប់សកម្មភាពផ្សេងៗទៀតពាក់ព័ន្ធនឹងការផ្តល់សេវាទូរគមនាគមន៍ ដូចមានចែងក្នុងប្រការ ៦, ប្រការ ៧, ប្រការ ៨ និង ប្រការ ៩ នៃប្រកាសនេះ ។

### ផ្នែកទី ២
### លក្ខខណ្ឌ និង នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត

**ប្រការ ៦.-**

ក) បុគ្គលទាំងឡាយជាជនជាតិខ្មែរ ឬ ជនជាតិបរទេសដែលមានបំណងបំពេញប្រតិបត្តិការដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់ស្តីពីទូរគនាគមន៍ ត្រូវដាក់ពាក្យស្នើសុំទៅ

ន.ទ.ក. តាមទម្រង់បែបបទ ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ និងត្រូវអនុវត្តតាម លក្ខខណ្ឌ និង នីតិវិធី ដូចតទៅ ៖

១) បំពេញទម្រង់បែបបទពាក្យស្នើសុំ ដោយភ្ជាប់ជាមួយនូវឯកសារកំណត់ សម្រាប់ប្រភេទប្រតិបត្តិការនីមួយៗ,

២) បង់កម្រៃដាក់ពាក្យស្នើសុំតាមការកំណត់ ។

ខ) ន.ទ.ក. ត្រូវបដិសេធការដាក់ពាក្យស្នើសុំ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំ ៖

១) ពុំបានបំពេញទម្រង់បែបបទត្រឹមត្រូវ ឬ មិនផ្តល់ឯកសារបន្ថែមតាមការ តម្រូវ ។

២) ពុំបង់កម្រៃដាក់ពាក្យស្នើសុំតាមការកំណត់ ។

គ) ន.ទ.ក. ត្រូវផ្តល់លិខិតអនុញ្ញាតតាមគំរូដែលបានកំណត់ជូនអ្នកដាក់ពាក្យស្នើសុំ ដែលបានបំពេញទម្រង់បែបបទត្រឹមត្រូវនិងគ្រប់គ្រាន់ ពុំលើសពី ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ ។ ន.ទ.ក. មានពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការបន្ថែមទៀតសម្រាប់ពិនិត្យពាក្យស្នើសុំដែលបាន កែតម្រូវ និង/ឬ បំពេញឯកសារ ឬ ផ្តល់ព័ត៌មានបន្ថែម ។

## ផ្នែកទី ៣
## លក្ខខណ្ឌ និង នីតិវិធីនៃការផ្តល់វិញ្ញាបនបត្រ

**ប្រការ ៧.-**

ក) បុគ្គលទាំងឡាយជាជនជាតិខ្មែរ ឬ ជនជាតិបរទេសដែលមានបំណងបំពេញ ប្រតិបត្តិការដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់ស្តីពីទូរគមនាគមន៍ ត្រូវដាក់ពាក្យស្នើសុំនៅ ន.ទ.ក. តាមទម្រង់បែបបទដូចមានចែងក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ និងត្រូវអនុវត្តតាម លក្ខខណ្ឌ និង នីតិវិធី ដូចតទៅ ៖

១) បំពេញទម្រង់បែបបទពាក្យស្នើសុំ ដោយភ្ជាប់ជាមួយនូវឯកសារកំណត់ សម្រាប់ប្រភេទប្រតិបត្តិការនីមួយៗ

២) បង់កម្រៃដាក់ពាក្យស្នើសុំតាមការកំណត់ ។

ខ) ន.ទ.ក.ត្រូវបដិសេធការដាក់ពាក្យស្នើសុំ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំ ៖

១) ពុំបានបំពេញទម្រង់បែបបទត្រឹមត្រូវ ឬ មិនផ្តល់ឯកសារបន្ថែមតាមការ តម្រូវ ។

២) ពុំបង់កម្រៃដាក់ពាក្យស្នើសុំតាមការកំណត់ ។

គ) ន.ទ.ក. ត្រូវផ្តល់វិញ្ញាបនបត្រតាមគំរូដែលបានកំណត់ជូនអ្នកដាក់ពាក្យស្នើសុំដែលបានបំពេញទម្រង់បែបបទត្រឹមត្រូវនិងគ្រប់គ្រាន់ ពុំលើសពី ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ។ ន.ទ.ក. មានពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ថែមទៀត សម្រាប់ពិនិត្យពាក្យស្នើសុំដែលបានកែតម្រូវ និង/ឬ បំពេញឯកសារ ឬ ផ្តល់ព័ត៌មានបន្ថែម ។

**ប្រការ ៨.-**

ក) អនុលោមតាមមាត្រា ៣៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ ក.ប.ទ. នឹងរៀបចំតាមការស្នើរបស់ ន.ទ.ក. នូវបញ្ជីគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍សម្រាប់ផ្តល់វិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ ដោយ ៖

១) បញ្ជីគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ដែលតម្រូវឱ្យសុំវិញ្ញាបនបត្រ ត្រូវផ្សព្វផ្សាយដោយ ន.ទ.ក. ។

២) បញ្ជីថ្មី ឬ បញ្ជីបន្ថែមនូវគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ដែលបង្កការធ្ងន់ធ្ងរ ប៉ះពាល់ដល់សន្តិសុខជាតិ និង ផលប្រយោជន៍សាធារណៈ ដែលតម្រូវឱ្យសុំវិញ្ញាបនបត្រ ត្រូវបញ្ចូលបន្ថែមទៅក្នុងសេចក្តីជូនដំណឹង ហើយអាចនឹងកែសម្រួល ឬ បំពេញបន្ថែមតាមការចាំបាច់ដោយ ក.ប.ទ. ។

៣) លក្ខខណ្ឌទូទៅនៃវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ ត្រូវកំណត់តាមប្រភេទនីមួយៗ។

ខ) មុននឹងដំឡើងនិងបំពាក់គ្រឿងសម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ និង កាន់កាប់ បុគ្គលទាំងឡាយជាជនជាតិខ្មែរ ឬ ជនជាតិបរទេសត្រូវបំពេញទម្រង់បែបបទសុំចុះបញ្ជីឱ្យបានត្រឹមត្រូវ និង ដាក់ពាក្យស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៅ ន.ទ.ក. ។

គ) ន.ទ.ក. និង អ្នកដាក់ពាក្យស្នើសុំត្រូវអនុវត្តតាមនីតិវិធីចុះបញ្ជីដូចតទៅ ៖

១) ន.ទ.ក. ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីព័ត៌មានចាំបាច់ និង ឯកសារសំខាន់ៗ សម្រាប់ចុះបញ្ជី និង អាចកែសម្រួលបន្តបន្ទាប់តាមការចាំបាច់ ។

២) ទម្រង់បែបបទនៃការចុះបញ្ជីតាមស្តង់ដាតែមួយ ដោយចែងអំពីរាល់ព័ត៌មានចាំបាច់ដែលអ្នកដាក់ពាក្យស្នើសុំត្រូវបំពេញ ដូចមានចែងក្នុងឧសម្ព័ន្ធទី៣។

៣) អ្នកដាក់ពាក្យស្នើសុំត្រូវបង់កម្រៃចុះបញ្ជី និង កម្រៃពាក់ព័ន្ធដទៃទៀត

សម្រាប់ថ្ងៃសេវារដ្ឋបាលតាមការកំណត់។

៤) ក្រោយពេលបានបំពេញនិងចុះហត្ថលេខាត្រឹមត្រូវលើពាក្យស្នើសុំចុះបញ្ជី ព្រមទាំងបានបង់កម្រៃពាក់ព័ន្ធជូន ន.ទ.ក. រួចរាល់ អ្នកដាក់ពាក្យស្នើសុំដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមបទប្បញ្ញត្តិកំណត់ នឹងបានទទួលវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ ។

៥) ន.ទ.ក. ត្រូវផ្តល់វិញ្ញាបនបត្រតាមគំរូដែលបានកំណត់ជូនអ្នកដាក់ពាក្យស្នើសុំដែលបានបំពេញទម្រង់បែបបទត្រឹមត្រូវនិងគ្រប់គ្រាន់ ពុំលើសពី ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ។ ន.ទ.ក. មានពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ថែមទៀត សម្រាប់ពិនិត្យពាក្យស្នើសុំដែលបានកែតម្រូវ និង/ឬ បំពេញឯកសារ ឬ ផ្តល់ព័ត៌មានបន្ថែម ។

៦) ន.ទ.ក.ត្រូវបដិសេធការដាក់ពាក្យស្នើសុំ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំ ៖
- ពុំបានបំពេញទម្រង់បែបបទត្រឹមត្រូវ ឬ មិនផ្តល់ឯកសារបន្ថែមតាមការតម្រូវ ។
- ពុំបង់កម្រៃដាក់ពាក្យស្នើសុំតាមការកំណត់ ។

ឃ ) អ្នកទទួលវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទលើគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ ត្រូវ ៖

១) កាន់កាប់ និង ប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍នៅត្រឹមតែក្នុងវង្វង់នៃតំបន់ ឬ ទីតាំងដែលបានអនុញ្ញាតនៅក្នុងវិញ្ញាបនបត្រប៉ុណ្ណោះ

២) មានវិធានការបង្ការឱ្យបាននូវរាល់ការរំខាន ប្រតិបត្តិកាទូរគមនាគមន៍នៃប្រតិបត្តិករដទៃ ពិសេសសុវត្ថិភាពសាធារណៈ សង្គម និង សន្តិសុខជាតិ,

៣) អនុវត្តតាមការណែនាំរបស់ ន.ទ.ក. ទាក់ទងនឹងការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និងវិ ទ្យុគមនាគមន៍

៤) បដិបត្តិតាមស្តង់ដាបច្ចេកទេសតម្រូវ ដែលកំណត់នៅក្នុងបទប្បញ្ញត្តិផ្សេងទៀតចេញដោយ ន.ទ.ក. ។

## ផ្នែកទី ៤
## លក្ខខណ្ឌ និង នីតិវិធីនៃការផ្ដល់អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍

**ប្រការ ៩.-**

បុគ្គលទាំងឡាយជាជនជាតិខ្មែរ ឬ ជនជាតិបរទេស ដែលមានបំណងបំពេញប្រតិបត្តិការដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្ដីពីទូរគនាគមន៍ ត្រូវដាក់ពាក្យស្នើសុំទៅ ន.ទ.ក.តាមទម្រង់បែបបទ ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ និងត្រូវអនុវត្តតាមលក្ខខណ្ឌ និងនីតិវិធី ដូចតទៅ ៖

***ក) លក្ខខណ្ឌ និង នីតិវិធីនៃការផ្ដល់អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា និង អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ រួមមាន៖***

អនុលោមតាមផ្នែកទី២ ជំពូក២ នៃច្បាប់ស្ដីពីទូរគមនាគមន៍ អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា ឬ អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ត្រូវបំពេញទម្រង់បែបបទស្របតាមនីតិវិធីជរមាន ។

១) អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញទម្រង់បែបបទដូចតទៅ ៖

- ដាក់ពាក្យស្នើសុំអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា ដាច់ដោយឡែកពីអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់,
- បំពេញព័ត៌មានឱ្យបានត្រឹមត្រូវ និង ភ្ជាប់ឯកសារសំខាន់ៗឱ្យបានគ្រប់គ្រាន់,
- លើកលែងតែមានបដិប្បញ្ញត្តិនឹងប្រកាសនេះ អ្នកដាក់ពាក្យស្នើសុំត្រូវបង់កម្រៃដាក់ពាក្យស្នើសុំតាមការកំណត់។

២) ក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើមានមូលដ្ឋានគ្រប់គ្រាន់និងពិនិត្យឃើញថា ព័ត៌មានដែលបានបំពេញនៅក្នុងពាក្យស្នើសុំពុំទាន់ត្រឹមត្រូវ ឬ មិនគ្រប់គ្រាន់ ន.ទ.ក. ត្រូវផ្ដល់ដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំ ដោយបញ្ជាក់អំពីភាពពុំទាន់ត្រឹមត្រូវ ឬ ព័ត៌មានចាំបាច់ត្រូវបំពេញបន្ថែម ។ អ្នកដាក់ពាក្យស្នើសុំត្រូវកែតម្រូវ ឬ បំពេញភាពខ្វះចន្លោះនៃពាក្យស្នើសុំតាមការតម្រូវរបស់ ន.ទ.ក. ក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង។ ក្នុងរយៈពេលនេះ

អ្នកដាក់ពាក្យស្នើសុំអាចដាក់លិខិតសុំពន្យារពេលដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ។ ពុំនោះសោត ពាក្យស្នើសុំនឹងក្លាយជាមោឃៈដោយស្វ័យប្រវត្តិ ។

៣) ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការក្រោយពីបានទទួលពាក្យស្នើសុំ ន.ទ.ក. ត្រូវពិនិត្យពាក្យស្នើសុំដែលបានបំពេញត្រឹមត្រូវ និង ភ្ជាប់ឯកសារគ្រប់គ្រាន់ រួចផ្តល់ដំណឹងទៅអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរអំពីការសម្រេចផ្តល់ជូន ឬ បដិសេធ ។ ន.ទ.ក. ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំដែលបានបំពេញត្រឹមត្រូវ និង ភ្ជាប់ឯកសារគ្រប់គ្រាន់ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់នៃការពន្យារពេលពិនិត្យពាក្យស្នើសុំលើសពី ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ ។ ន.ទ.ក. ត្រូវបញ្ចប់ការពិនិត្យ និង សម្រេចលើពាក្យស្នើសុំ ពុំលើសរយៈពេល ៦០ (ហុកសិប) ថ្ងៃ ក្រោយកាលបរិច្ឆេទផ្តល់ដំណឹងអំពីការពន្យារពេល។

៤) ការផ្តល់ដំណឹងអំពីការសម្រេចរបស់ ន.ទ.ក. ទៅអ្នកដាក់ពាក្យស្នើសុំ រួមមាន ៖

- ការបង់កម្រៃពាក់ព័ន្ធ ប្រសិនបើពាក្យស្នើសុំបានទទួលការអនុម័តយល់ព្រម,
- ការបដិសេធដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងពុំលម្អៀង ។

៥) អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា និង/ឬ អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ ត្រូវផ្តល់ដោយពុំមានគោលការណ៍ផ្តាច់មុខ និង មិនកំណត់ចំនួនអាជ្ញាបណ្ណមុនឡើយ ។ ក.ប.ទ. អាចនឹងសម្រេចកំណត់អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា និង អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ ស្របតាមការស្នើរបស់ ន.ទ.ក.ដោយផ្អែកលើហេតុផលត្រឹមត្រូវ និង ច្បាស់លាស់ ដូចជា ការដាក់កំហិត ឬ ការកម្រិតការប្រើប្រាស់ធនធានកម្រ ។ ការសម្រេចកំណត់ចំនួនអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា ឬ អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ អាចប្រព្រឹត្តទៅបាន លុះត្រាតែបានផ្តល់ឱកាសវេលាសមស្របសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ និង ភាគីពាក់ព័ន្ធផ្តល់មតិតាមរយៈការពិគ្រោះយោបល់សាធារណៈ។

៦) អនុលោមតាមបទប្បញ្ញត្តិផ្សេងទៀត និង ការកំណត់បែងចែកដោយ ន.ទ.ក. អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញទម្រង់បែបបទដាច់ដោយឡែកពីគ្នាសម្រាប់ដាក់ពាក្យស្នើសុំ៖

- ប្រើប្រាស់លេខទូរស័ព្ទ និង លេខទូរគមនាគមន៍
- អាជ្ញាបណ្ណធនធានវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ

លិខិតអនុញ្ញាត ឬ អាជ្ញាបណ្ណនីមួយៗខាងលើ ពុំមានប្រសិទ្ធភាពប្រើប្រាស់ជំនួសគ្នាឡើយ ។

៧) អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា អនុញ្ញាតឱ្យអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណ ស្ថាបនា និង ប្រតិបត្តិការបណ្តាញទូរគមនាគមន៍ និង ប្រតិបត្តិការសេវាទូរគមនាគមន៍សម្រាប់ផ្តល់ជូនសាធារណជន និង ឯកជនតាមរយៈបណ្តាញ ដូចមានចែងលម្អិតនៅក្នុងឧបសម្ព័ន្ធទី ៥(ក) នៃប្រកាសនេះ និងមានសិទ្ធិប្រើប្រាស់វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ និងប្លង់លេខទូរគមនាគមន៍ ។ អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាជាអាជ្ញាបណ្ណមានកម្រិតខ្ពស់បំផុត និង អនុញ្ញាតឱ្យអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណប្រើប្រាស់គ្រប់បច្ចេកវិទ្យាក្នុងការស្ថាបនា និង ប្រតិបត្តិការបណ្តាញទូរគមនាគមន៍គ្រប់ប្រភេទ ។ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណនេះ អាចផ្តល់សេវាទូរគមនាគមន៍គ្រប់ប្រភេទ ដូចមានចែងលម្អិតនៅក្នុងឧបសម្ព័ន្ធទី៥ (ក) (ខ) និង (គ) និងសម្រាប់សេវាទូរគមនាគមន៍ថ្មីផ្សេងៗទៀត ដែលត្រូវផ្តល់អនុញ្ញាតស្របតាមនីតិវិធីកំណត់នៅក្នុងចំណុច ៩ ខាងក្រោម ។

៨) អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ អនុញ្ញាតឱ្យអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណ ស្ថាបនា និង ប្រតិបត្តិការបណ្តាញ ទូរគមនាគមន៍ ដែលមានតែហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍អកម្ម ដូចមានចែងលម្អិតក្នុងឧបសម្ព័ន្ធទី៥ (ខ) នៃប្រកាសនេះ សម្រាប់ជួលឱ្យអ្នកទទួលអាជ្ញាបណ្ណដទៃផ្តល់សេវាទូរគមនាគមន៍នៅលើបណ្តាញរបស់ខ្លួន ឬ សម្រាប់ប្រតិបត្តិការផ្ទាល់ខ្លួន ។ អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ពុំអនុញ្ញាតឱ្យ (១) ប្រើប្រាស់ធនធានកម្រដូចជាវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ និង ប្លង់លេខទូរគមនាគមន៍, (២) តភ្ជាប់បណ្តាញបមាណីទូរស័ព្ទសាធារណៈ

ឬ ផ្តល់សេវាសំឡេងមូលដ្ឋាន ឬ សេវាសំឡេងអចល័ត តាមរយៈហេដ្ឋារចនាសម្ព័ន្ធ ឬ កម្មវិធីគ្រប់ប្រភេទឡើយ ។ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសេវាទូរគមនាគមន៍ បន្ថែម ។ ក្នុងករណីនេះ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណមានសិទ្ធិកាន់កាប់អាជ្ញាបណ្ណច្រើនបំផុតតែ ២ (ពីរ) ប៉ុណ្ណោះ ។

៩ ) ប្រសិនបើក្រោមវិសាលភាពនៃអាជ្ញាបណ្ណរបស់ខ្លួន ស្របតាមប្រភេទនៃអាជ្ញាបណ្ណដូចមានចែងក្នុងឧបសម្ព័ន្ធទី៥ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ឬ ផ្តល់សេវា-ទូរគមនាគមន៍បន្ថែម ចំពោះសេវាដែលពុំទាន់អនុវត្ត មក ន.ទ.ក. ដោយភ្ជាប់ជាមួយនូវលិខិតលាយលក្ខណ៍អក្សរបញ្ជាក់អំពីមូលហេតុ និង សក្ខីកម្មថាអាចបំពេញលក្ខខណ្ឌ និង/ឬកាតព្វកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការបន្ថែម ។ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណអាចចាប់ផ្តើមធ្វើប្រតិបត្តិការបន្ថែមក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃក្រោយពីបានដាក់ពាក្យស្នើសុំ លើកលែងតែ ន.ទ.ក. ផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរបដិសេធពាក្យស្នើសុំ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ និង ពុំលម្អៀង ។ ការអនុវត្តនេះ មិនគ្របដណ្តប់លើហេដ្ឋារចនាសម្ព័ន្ធនិងសេវា ដែលមានចែងក្នុងចំណុច (១១) ខាងក្រោមទេ ។

១០ ) ប្រសិនបើក្រោមវិសាលភាពអាជ្ញាបណ្ណរបស់ខ្លួន តែពុំមានចែងនៅក្នុងបញ្ជីសេវាអនុញ្ញាតសម្រាប់ប្រភេទអាជ្ញាបណ្ណដូចមានចែងក្នុងឧបសម្ព័ន្ធទី ៥ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ថ្មី ឬ ផ្តល់សេវាទូរគមនាគមន៍បន្ថែម មក ន.ទ.ក. ។ ពាក្យស្នើសុំត្រូវបញ្ជាក់អំពីមូលហេតុ និងសក្ខីកម្មថា អាចបំពេញលក្ខខណ្ឌ និង/ឬកាតព្វកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការបន្ថែម។ ន.ទ.ក. ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃក្រោយពីបានទទួលពាក្យស្នើសុំ ។ ការសម្រេចរបស់ ន.ទ.ក. ត្រូវស្របតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច (១១) ខាងក្រោម លើកលែងតែហេដ្ឋារចនាសម្ព័ន្ធនិងសេវាទូរគមនាគមន៍ដែលដាក់ពាក្យស្នើសុំនោះ តម្រូវឱ្យផ្តល់ដំណឹងសាធារណៈទៅអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណទាំងអស់ ស្របតាមលក្ខខណ្ឌកំណត់ចំនួន

អាជ្ញាបណ្ណដែលបានទទួលអនុញ្ញាតឱ្យស្ថាបនា និង ប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ និងសេវាទាំងនោះ ។

១១ ) ប្រសិនបើអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ ឬសេវាដែលត្រូវកំណត់ចំនួនដូចមានចែងក្នុងចំណុច (១០) ខាងលើ ន.ទ.ក. មានសិទ្ធិ (១) បដិសេធពាក្យស្នើសុំប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធនិងសេវា ដែលពុំមានចែងនៅក្នុងបញ្ជីសេវាតាមប្រភេទអាជ្ញាបណ្ណនៅក្នុងឧបសម្ព័ន្ធទី៥ ឬ (២) ផ្សព្វផ្សាយឱ្យដាក់ពាក្យស្នើសុំ ឬ ដាក់ពាក្យដេញថ្លៃសិទ្ធិធ្វើប្រតិបត្តិការសេវាដែល ក.ប.ទ. ត្រូវរៀបចំបទប្បញ្ញត្តិដោយឡែកតាមការស្នើរបស់ ន.ទ.ក. ។

**ខ) លក្ខខណ្ឌ និង នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណសេវាទូរគមនាគមន៍**

អនុលោមតាមផ្នែកទី ២ ជំពូក ៤ នៃច្បាប់ស្តីពីទូរគមនាគមន៍ អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសេវាទូរគមនាគមន៍ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ន.ទ.ក. ។ នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីងាយស្រួលជាងការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា ។

១ ) អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញទម្រង់បែបបទដូចតទៅ៖

- បំពេញពាក្យស្នើសុំចុះបញ្ជី
- បំពេញព័ត៌មានឱ្យបានត្រឹមត្រូវ និង ភ្ជាប់ឯកសារសំខាន់ៗឱ្យបានគ្រប់គ្រាន់
- លើកលែងតែមានបដិប្បញ្ញត្តិនឹងប្រកាសនេះ អ្នកដាក់ពាក្យស្នើសុំត្រូវបង់កម្រៃដាក់ពាក្យស្នើសុំតាមការកំណត់។

២ ) ន.ទ.ក. ត្រូវផ្តល់អាជ្ញាបណ្ណសេវាទូរគមនាគមន៍ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលពិនិត្យឃើញថា អ្នកដាក់ពាក្យស្នើសុំបានចុះហត្ថលេខាត្រឹមត្រូវ និង ផ្តល់ព័ត៌មានគ្រប់គ្រាន់ ព្រមទាំងបានបង់កម្រៃពាក់ព័ន្ធតាមការកំណត់រួចរាល់ ។

៣ ) ន.ទ.ក. ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរអំពីការពុំទទួលចុះបញ្ជីប្រសិនបើអ្នកដាក់ពាក្យស្នើសុំ ៖

- ពុំចុះហត្ថលេខាត្រឹមត្រូវ ព័ត៌មានមិនគ្រប់គ្រាន់ និង ខ្វះចន្លោះនូវលក្ខណៈវិនិច្ឆ័យចម្បងៗ,
- ពុំបង់កម្រៃពាក់ព័ន្ធតាមការកំណត់ ។

៤) ក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើមានមូលដ្ឋានគ្រប់គ្រាន់ និងពិនិត្យឃើញថា ព័ត៌មានដែលបានបំពេញនៅក្នុងពាក្យស្នើសុំពុំគ្រប់គ្រាន់ ន.ទ.ក. ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំ។ អ្នកដាក់ពាក្យស្នើសុំត្រូវកែតម្រូវ ឬ បំពេញភាពខ្វះចន្លោះតាមការតម្រូវរបស់ ន.ទ.ក. ក្នុងរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង។ ក្នុងរយៈពេលនេះ អ្នកដាក់ពាក្យស្នើសុំអាចដាក់លិខិតសុំពន្យារពេលដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ។ ពុំនោះសោតពាក្យស្នើសុំនឹងក្លាយជាមោឃៈដោយស្វ័យប្រវត្តិ ។

៥) ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីបានទទួលពាក្យស្នើសុំ ន.ទ.ក. ត្រូវពិនិត្យពាក្យស្នើសុំដែលបានបំពេញព័ត៌មានត្រឹមត្រូវ និង ភ្ជាប់ឯកសារគ្រប់គ្រាន់ រួចជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរអំពីការសម្រេចផ្តល់ជូន ឬ បដិសេធ ។ ន.ទ.ក. ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំដែលបានបំពេញត្រឹមត្រូវ និង ភ្ជាប់ឯកសារគ្រប់គ្រាន់ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់នៃការពន្យារពេលពិនិត្យពាក្យស្នើសុំលើសពី ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ ។ ន.ទ.ក. ត្រូវបញ្ចប់ការពិនិត្យ និង សម្រេចលើពាក្យស្នើសុំ ពុំលើសរយៈពេល ៣០ (សាមសិប) ថ្ងៃក្រោយកាលបរិច្ឆេទផ្តល់ដំណឹងអំពីការពន្យារពេលឡើយ ។

៦) ប្រសិនបើយល់ព្រមទទួលចុះបញ្ជី ន.ទ.ក. ត្រូវផ្តល់អាជ្ញាបណ្ណពាក់ព័ន្ធតាមនីតិវិធីជរមាន ។ ក្នុងករណីបដិសេធពុំទទួលចុះបញ្ជី ន.ទ.ក. ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ និង ពុំលម្អៀង ។

៧) ការផ្តល់អាជ្ញាបណ្ណសេវាទូរគមនាគមន៍ ពុំមានកំណត់ចំនួនទេ លើកលែងតែមានចែងដោយបទប្បញ្ញត្តិផ្សេងទៀត ។

៨) អាជ្ញាបណ្ណសេវាទូរគមនាគមន៍ អនុញ្ញាតឱ្យអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណបំពេញប្រតិបត្តិការត្រឹមតែសកម្មភាពទាំងឡាយណាមានចែងលម្អិតនៅក្នុងឧបសម្ព័ន្ធទី៥(គ) នៃប្រកាសនេះ។ ចំពោះប្រតិបត្តិការផ្តល់សេវាទូរគមនាគមន៍ផ្សេងទៀត អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណអាច ៖

- ជួលជាវហេដ្ឋារចនាសម្ព័ន្ធពីអ្នកទទួលអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា ឬ

- ដាក់ពាក្យស្នើសុំ និង ទទួលអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ ។ ក្នុងករណីនេះ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណមានសិទ្ធិកាន់កាប់អាជ្ញាបណ្ណច្រើនបំផុតតែ ២ (ពីរ) ប៉ុណ្ណោះ ។

៩ ) អាជ្ញាបណ្ណសេវាទូរគមនាគមន៍ ពុំអនុញ្ញាតឱ្យអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណ ៖

- ស្ថាបនា និងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធឬបណ្តាញទូរគមនាគមន៍
- ប្រើប្រាស់វិសាលគមន៍ប្រេកង់ស៍វិទ្យុ លើកលែងតែមានការកំណត់ក្នុងបទប្បញ្ញត្តិផ្សេងទៀត
- ប្រើប្រាស់ប្លង់លេខទូរគមនាគមន៍ លើកលែងតែអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណសេវាទូរគមនាគមន៍ ដែលប្រតិបត្តិការសេវា VoIP
- តភ្ជាប់បណ្តាញបមាណីទូរស័ព្ទសាធារណៈ ឬ ផ្តល់សេវាសំឡេងមូលដ្ឋាន ឬ សេវាសំឡេងអចល័តតាមរយៈហេដ្ឋារចនាសម្ព័ន្ធ ឬ កម្មវិធីគ្រប់ប្រភេទឡើយ ។

## ជំពូកទី ៣
## ការកែប្រែ ឬ ការបំពេញបន្ថែម បដិសេធន៍ និង ការលើកលែងក្នុងការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង អាជ្ញាបណ្ណទូរគមនាគមន៍

**ប្រការ ១០.-**

អនុលោមតាមចំណុច (ខ) មាត្រា ២០ នៃច្បាប់ស្តីពីទូរគមនាគមន៍ មុននឹងកែប្រែ ឬ បំពេញបន្ថែមលក្ខខណ្ឌប្រែប្រួលថ្មីលើលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ដែលកំពុងមានសុពលភាពស្របតាមច្បាប់ស្តីពីទូរគមនាគមន៍ និង បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ន.ទ.ក. ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅប្រតិបត្តិករទូរគមនាគមន៍ អ្នកកាន់អាជ្ញាបណ្ណ និង បុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍រយៈពេល ១ (មួយ) ឆ្នាំ ។

**ប្រការ ១១.-**

ន.ទ.ក. មានសិទ្ធិធ្វើការបដិសេធដល់អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍បាន បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីហេតុផលនៃការបដិសេធជូនដល់អ្នកដាក់ពាក្យស្នើសុំ និងបានផ្តល់ឱកាសរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការសម្រាប់អ្នកដាក់ពាក្យស្នើសុំធ្វើការផ្តល់យុត្តិកម្ម។

**ប្រការ ១២.-**

ន.ទ.ក. មានសិទ្ធិសម្រេចលើកលែងសេវាទូរគមនាគមន៍មួយចំនួនពីកាតព្វកិច្ចសុំអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ស្របតាមការកំណត់របស់ ក.ប.ទ. ដោយផ្អែកលើមូលហេតុត្រឹមត្រូវ ច្បាស់លាស់ ប្រកបដោយតម្លាភាព និង មិនលំអៀង។ ន.ទ.ក. ត្រូវផ្សព្វផ្សាយសាធារណៈអំពីការសម្រេចនេះនៅលើគេហទំព័ររបស់ខ្លួន ។

**ប្រការ ១៣.-**

អនុលោមតាមផ្នែកទី ៣ ជំពូក ៥ នៃច្បាប់ស្តីពីទូរគមនាគមន៍ ប្រតិបត្តិករទូរគមនាគមន៍ អ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណ និង បុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ត្រូវធ្វើប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធបណ្តាញ និង ប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍និងវិទ្យុគមនាគមន៍ ឱ្យស្របតាមស្តង់ដាបច្ចេកទេសកំណត់ ។

**ប្រការ ១៤.-**

អនុលោមតាមចំណុច (គ) និង (ឃ) មាត្រា ១២ នៃច្បាប់ស្តីពីទូរគមនាគមន៍ ន.ទ.ក. មានសិទ្ធិសុំ ក.ប.ទ. ធ្វើវិសោធនកម្មបទប្បញ្ញត្តិ ឬ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការកំណត់លក្ខខណ្ឌ និង នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ និងចេញសេចក្តីសម្រេចបន្ថែមទៅលើបទប្បញ្ញត្តិ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកំណត់លក្ខខណ្ឌ និង នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ស្របតាមច្បាប់។

មុននឹងកែប្រែ ឬបំពេញបន្ថែម ឬធ្វើវិសោធនកម្ម ន.ទ.ក. ត្រូវផ្តល់ឱកាសវេលាគ្រប់គ្រាន់សម្រាប់ប្រតិបត្តិករទូរគមនាគមន៍ អ្នកកាន់អាជ្ញាបណ្ណ និង បុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ចូលរួមពិគ្រោះយោបល់ជាសាធារណៈ ។

## ជំពូកទី ៤

## ការផ្តល់សុពលភាព ការបន្តឬពន្យារពេល បដិសេធន៍ ការផ្ទេរឬការរំលាយបញ្ចូលគ្នា ការកែប្រែ ការព្យួរ ការបោះបង់ចោល និង ការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍

**ប្រការ ១៥.-**

ន.ទ.ក. ត្រូវផ្តល់ជូនអ្នកដាក់ពាក្យស្នើសុំថ្មីក្រោមវិសាលភាពនៃប្រកាសនេះនូវសុពលភាពកំណត់តាមយថាប្រភេទដូចតទៅ ៖

ក) រយៈពេល ០១ (មួយ) ឆ្នាំ ចំពោះលិខិតអនុញ្ញាត និង វិញ្ញាបនបត្រដូចមានចែងក្នុងមាត្រា ១៥ និង មាត្រា ១៦ នៃច្បាប់ស្តីពីទូរគមនាគមន៍ លើកលែងវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និងគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍មានសុពលភាពអចិន្ត្រៃយ៍ ។

ខ) សុពលភាព ៣០ (សាមសិប) ឆ្នាំ ចំពោះអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ និង សេវា និង/ឬ អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ ។ ន.ទ.ក. មានសិទ្ធិត្រួតពិនិត្យសុពលភាពនៃអាជ្ញាបណ្ណនេះឡើងវិញរៀងរាល់ ១០ (ដប់) ឆ្នាំម្តង ។

គ) សុពលភាព ១៥ (ដប់ប្រាំ)ឆ្នាំ ចំពោះអាជ្ញាបណ្ណសេវាទូរគមនាគមន៍ ។ ន.ទ.ក. មានសិទ្ធិត្រួតពិនិត្យសុពលភាពនៃអាជ្ញាបណ្ណនេះឡើងវិញរៀងរាល់ ០៥ (ប្រាំ) ឆ្នាំម្តង ។

**ប្រការ ១៦**._

ក) មុនផុតសុពលភាពនៃអាជ្ញាបណ្ណ ១២ (ដប់ពីរ) ខែ ប្រសិនបើមានបំណងដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍គ្រប់ប្រភេទ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរនៅ ន.ទ.ក. ដោយភ្ជាប់ជាមួយនូវព័ស្តុតាងបញ្ជាក់អំពីការអនុវត្តខ្ជាប់ខ្ជួនតាម ៖

១) ច្បាប់ស្តីពីទូរគមនាគមន៍,

២) ក្របខ័ណ្ឌនិយ័តកម្មពាក់ព័ន្ធ រួមមានច្បាប់ បទប្បញ្ញត្តិ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជរមានដែលចេញដោយ ក.ប.ទ. ឬ ន.ទ.ក. ,

៣) លក្ខខណ្ឌ និង កាតព្វកិច្ចដែលចែងនៅក្នុងអាជ្ញាបណ្ណពាក់ព័ន្ធ ។

ខ) ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការក្រោយពីទទួលពាក្យស្នើសុំបន្ត និងមិនមានការជំទាស់រវាង ន.ទ.ក. និងអ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ទេ ន.ទ.ក. ត្រូវសម្រេចអនុញ្ញាតបន្តសុពលភាពអាជ្ញាបណ្ណពាក់ព័ន្ធស្របតាមនីតិវិធីជរមានដោយរក្សា ឬ ផ្តល់លក្ខខណ្ឌប្រហាក់ប្រហែលគ្នានឹងអាជ្ញាបណ្ណដើម ដោយកំណត់សុពលភាពបន្ត តាមយថាប្រភេទដូចតទៅ៖

១) ១០ (ដប់) ឆ្នាំ ម្តង ចំពោះអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា និង អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ ។

២) ៥ (ប្រាំ) ឆ្នាំ ចំពោះអាជ្ញាបណ្ណសេវាទូរគមនាគមន៍ ។

អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណអាចសុំបន្តសុពលភាពតាមលំដាប់រៀងរហូតតាមលក្ខខណ្ឌ និង នីតិវិធីនៃប្រការ ១៦ នេះ ។

គ) មុនផុតសុពលភាពនៃលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ៣០ (សាមសិប) ថ្ងៃ ប្រសិនបើមានបំណងដាក់ពាក្យស្នើសុំបន្តលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រគ្រប់ប្រភេទ អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរនៅ ន.ទ.ក. លើកលែងវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ ។

**ប្រការ ១៧.-**

ប្រសិនបើសម្រេចបដិសេធពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ន.ទ.ក. ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំ ដោយ ៖

ក) បញ្ជាក់អំពីមូលហេតុច្បាស់លាស់ រួមមាន ៖

១) ការពុំបំពេញកាតព្វកិច្ចដូចមានចែងនៅក្នុងច្បាប់ស្តីពីទូរគមនាគមន៍,

២) ការមិនគោរពតាមសេចក្តីណែនាំរបស់ ន.ទ.ក. អំពីការប្រកួតប្រជែងដោយស្មើភាព និង ការប្រព្រឹត្តផ្ទុយពីគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ ។

៣) ការរំលោភលើសេចក្តីណែនាំរបស់ ន.ទ.ក. អំពីការដោះស្រាយវិវាទទាក់ទងនឹងការតភ្ជាប់បណ្តាញ ។

ខ) ផ្តល់ឱកាសសមស្របសម្រាប់អ្នកដាក់ពាក្យស្នើសុំកែតម្រូវ និង បំពេញចំណុចខ្វះខាត រួចដាក់ពាក្យស្នើសុំសាថ្មី ។

**ប្រការ ១៨.-**

មុននឹងផ្ទេរលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ដូចមានចែងក្នុងមាត្រា ១៥ មាត្រា ១៦ និង មាត្រា ១៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ និង/ឬ រំលាយក្រុមហ៊ុនបញ្ចូលគ្នា អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិ-ការទូរគមនាគមន៍ ត្រូវដាក់ពាក្យស្នើសុំនៅ ន.ទ.ក. ។

ក) ការដាក់ពាក្យស្នើសុំផ្ទេរត្រូវភ្ជាប់របាយការណ៍លម្អិតអំពីការស្រុះស្រួលគ្នា និង រូបភាព ព្រមទាំងកម្មវត្ថុនៃការផ្ទេររួមមាន ៖

១) ការផ្ទេរតាមរយៈវិធីសាស្ត្រនានាដោយរាប់បញ្ចូលទាំងកិច្ចសន្យា ការផ្ទេរកម្មសិទ្ធិ ការលក់ធុរកិច្ច ធនធានហិរញ្ញវត្ថុ ធនធានដទៃទៀត និង ប្រតិបត្តិការ

២) ការដាក់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ជាប្រាតិភោគ,

៣) ការទិញយកលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ។

ខ) ន.ទ.ក. មានសិទ្ធិបដិសេធពាក្យស្នើសុំផ្ទេរ ដោយបញ្ជាក់មូលហេតុច្បាស់លាស់ជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំ ប្រសិនបើពិនិត្យឃើញថា ៖

១) រំលោភគោលការណ៍ប្រកួតប្រជែងនៅក្នុងទីផ្សារដូចបានកំណត់ក្រោមវិសាលភាពនៃបទប្បញ្ញត្តិស្ដីពីប្រកួតប្រជែងកំពុងនៅជាធរមាន,

២) ប៉ះពាល់យ៉ាងធ្ងន់ចំពោះការផ្ដល់សេវាទូរគមនាគមន៍ជូនសាធារណជន ។

គ) ការដាក់ពាក្យស្នើសុំរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញយក ត្រូវភ្ជាប់របាយការណ៍លម្អិតអំពីការស្រុះស្រួលគ្នា ។ ន.ទ.ក.ត្រូវពិនិត្យ និង ផ្តល់អនុញ្ញាត ដោយពុំពន្យារពេល ប្រសិនបើពិនិត្យឃើញថា កម្មវត្ថុនៃការសុំមានគោលដៅ ៖

១) កែសម្រួលរចនាសម្ព័ន្ធផ្ទៃក្នុង,

២) កែប្រែរចនាសម្ព័ន្ធរបស់ក្រុមហ៊ុនថ្មីឱ្យមានភាពជាម្ចាស់ ។

**ប្រការ ១៩.-**

អនុលោមតាមចំណុច (ច) មាត្រា ១២ នៃច្បាប់ស្ដីពីទូរគមនាគមន៍ និង បទប្បញ្ញត្តិផ្សេងទៀត ន.ទ.ក. មានសិទ្ធិអំណាចក្នុងការកែប្រែ ព្យួរ ផ្ទេរ ឬ ដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ។ សិទ្ធិអំណាចនេះអនុវត្តក្នុងកាលៈទេសៈដូចតទៅ ៖

ក) តាមការសុំនៃអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍,

ខ) ចាត់វិធានការ តាមដាន និង ជំរុញការអនុវត្តតាមលក្ខខណ្ឌ និង កាតព្វកិច្ចដែលមានចែងនៅក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណពាក់ព័ន្ធ,

គ) ពង្រឹង និង ជំរុញការអនុវត្តច្បាប់ស្ដីពីទូរគមនាគមន៍ ប្រកាស បទប្បញ្ញត្តិ សេចក្ដីជូនដំណឹង និង សេចក្ដីសម្រេចពាក់ព័ន្ធដែលបានកែប្រែ ឬ បំពេញបន្ថែម ។

**ប្រការ ២០.-**

អនុលោមតាមមាត្រា ៧៨ នៃច្បាប់ស្ដីពីទូរគមនាគមន៍ និង ច្បាប់ ប្រកាស ឬ បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ន.ទ.ក. មានសិទ្ធិអំណាចចាត់វិធានការដូចតទៅ ៖

ក) បង្គាប់ឱ្យអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ អនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍,

ខ) ដាក់កំហិតអាជ្ញាបណ្ណ,

គ) ព្យួរលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណរហូតដល់អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍អនុវត្តគ្រប់គ្រាន់តាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែម ។

ក្នុងករណីរកឃើញថា អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍បានប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិ ពាក់ព័ន្ធជរមាន ន.ទ.ក. មានសិទ្ធិអំណាចចាត់វិធានការដូចតទៅ ៖

ក ) ព្យួរបណ្តោះអាសន្ន ឬ បញ្ឈប់ការងាររបស់នាយកចាត់ការទូទៅ អគ្គនាយក នាយកប្រតិបត្តិ សមាជិកនៃថ្នាក់ដឹកនាំ បុគ្គលិកជាន់ខ្ពស់ អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍,

ខ ) ជ្រើសរើស និង ផ្តល់សិទ្ធិជូនបុគ្គលមានសមត្ថកិច្ចស៊ើបអង្កេតសកម្មភាពធុរកិច្ច ឬ សកម្មភាពពាក់ព័ន្ធ ។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ជូន ន.ទ.ក. ដោយអនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាជាមួយ ន.ទ.ក. ។

គ ) ដាក់កំហិត ឬ បញ្ឈប់សកម្មភាពជាក់លាក់ណាមួយ ឬ ទូទៅរបស់អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ទោះបីសកម្មភាពទាំងនោះបានធ្វើឡើងស្រប ឬ មិនស្របតាមលក្ខខណ្ឌនៃអាជ្ញា-បណ្ណក៏ដោយ ។

មុននឹងចាត់វិធានការណាមួយដូចរៀបរាប់ខាងលើ ន.ទ.ក. ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីគោលបំណង មូលហេតុច្បាស់លាស់ និង ផ្តល់ឱកាសវេលាសមស្របឱ្យអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ បង្ហាញព័ស្តុតាងពន្យល់អំពីសកម្មភាពរបស់ខ្លួន និង កែតម្រូវសកម្មភាពឡើងវិញ ។

**ប្រការ ២១.-**

មុននឹងបោះបង់ចោលប្រភេទណាមួយនៃអាជ្ញាបណ្ណ ត្រូវមានឯកភាពពី ន.ទ.ក. ស្របតាមនីតិវិធីជរមាន ។ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណត្រូវប្រឹងប្រែងឲ្យអស់លទ្ធភាពផ្ទេរអ្នកប្រើប្រាស់ទាំងអស់ទៅប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍ដទៃ ។ ការបោះបង់ប្រភេទនីមួយៗនៃអាជ្ញាបណ្ណត្រូវកំណត់ដូចតទៅៈ

ក) ដាក់ពាក្យស្នើសុំយ៉ាងតិច ១៨០ (មួយរយប៉ែតសិប) ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទបោះបង់អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា ។

ខ) ជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច ៩០ (កៅសិប) ថ្ងៃនៃថ្ងៃធ្វើការមុនកាលបរិច្ឆេទបោះបង់អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ ឬ អាជ្ញា-បណ្ណសេវាទូរគមនាគមន៍ ។

**ប្រការ ២២.-**

ន.ទ.ក. មានសិទ្ធិដកហូត ឬ លុបចោលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍គ្រប់ប្រភេទ ដោយអនុលោមតាមចំណុច (ប) មាត្រា ១២ នៃច្បាប់ស្តីពីទូរគមនាគមន៍ និង ក្នុងករណីដូចខាងក្រោមៈ

ក) អនុវត្តន៍សន្ធិសញ្ញាអន្តរជាតិ ការប្តេជ្ញាចិត្តក្នុងក្របខ័ណ្ឌអន្តរជាតិ ការបំពេញកាតព្វកិច្ចអន្តរជាតិ ស្របតាមច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។

ខ) អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ស្ម័គ្រចិត្តជម្រះបញ្ជី រំលាយបញ្ចូលគ្នា ឬ ត្រូវតុលាការបង្ខំឲ្យជម្រះបញ្ជី ។

គ) ការបំពេញទម្រង់បែបបទដាក់ពាក្យស្នើសុំ និង/ឬ ចុះបញ្ជីលិខិតអនុញ្ញាត វិញ្ញាបន-បត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ដោយបំភាន់ព័ត៌មាន រួមមាន ការក្លែងបន្លំព័ត៌មានខុសពីការពិត ឬ គេចវេះពីភាពទទួលខុសត្រូវចំពោះមុខច្បាប់ និងរដ្ឋ ។

ឃ) អ្នកកាន់ ឬ ទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ពុំអនុវត្តតាមលក្ខខណ្ឌដែលកំណត់នៅក្នុងច្បាប់ស្តីពីទូរគមនាគមន៍ បទប្បញ្ញត្តិ ពាក់ព័ន្ធ លិខិតអនុញ្ញាត វិញ្ញាបនបត្រ អាជ្ញាបណ្ណ កិច្ចសន្យា ការផ្តល់ជូន សេចក្តីស្នើសុំ និង រាល់កាតព្វកិច្ចទាំងឡាយណាដែល ៖

១) អ្នកផ្តល់សេវាពុំបានកែតម្រូវតាមការព្រមានរបស់ ន.ទ.ក. នូវរាល់អំពើដែលផ្ទុយនឹងបទប្បញ្ញត្តិក្នុងរយៈពេលកំណត់,

២) ការអនុវត្តផ្ទុយនឹងបទប្បញ្ញត្តិពាក់ព័ន្ធបានធ្វើឲ្យប៉ះពាល់អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ដទៃទៀត ប៉ះពាល់អតិថិជន ឬ ប៉ះពាល់ការប្រកួតប្រជែង,

៣) ការធ្វើឲ្យប៉ះពាល់ប្រសិទ្ធភាពនៃការជម្រះបញ្ជី ដោយរាប់បញ្ចូលទាំងការបង្ខំឲ្យទទួល និង ការផាកពិន័យ,

៤) អ្នកកាន់ ឬ ទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ពុំគោរពតាមនូវរាល់ការហាមឃាត់ ការព្យួរ ឬ បដិសេធន៍ ។

ន.ទ.ក.មានសិទ្ធិសម្រេចលុបលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ដោយអនុលោមតាមចំណុច (ច) មាត្រា ១២ នៃច្បាប់ស្តីពីទូរគមនាគមន៍តាមនីតិវិធីខាងក្រោម ៖

ក) មុននឹងលុបលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ណាមួយក្រោមវិសាលភាពនៃប្រកាសនេះ ន.ទ.ក. ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរអំពីគោលបំណងនៃការលុប និង ផ្តល់ឱកាសវេលាសមស្របសម្រាប់អ្នកកាន់ ឬ ទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ឆ្លើយតប ពន្យល់ ឬ បង្ហាញព័ស្តុតាង ។

ខ) ន.ទ.ក. ត្រូវពិចារណាឱ្យល្អិតល្អន់ចំពោះការឆ្លើយតប ការពន្យល់ ឬ ការបង្ហាញហេតុផលរបស់អ្នកកាន់ ឬ ទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ។

## ជំពូកទី ៥

## ការបង់កម្រៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ និង អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍

### ប្រការ ២៣.-

ក) អនុលោមតាមច្បាប់ស្តីពីទូរគមនាគមន៍ និង បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ត្រូវបង់កម្រៃ

ដែលត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រី ក.ប.ទ. ។ កម្រៃទាំងនោះរួមមាន៖

១) កម្រៃដាក់ពាក្យស្នើសុំ ឬ កម្រៃដាក់ពាក្យចុះបញ្ជី,

២) កម្រៃដំបូងដែលត្រូវបង់មុនពេលទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍,

៣) កម្រៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ប្រចាំឆ្នាំតាមភាគរយនៃចំណូលដុល ឬ ការកំណត់ណាមួយ,

៤) កម្រៃសុំបន្តលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍,

៥) កម្រៃសម្រាប់ផ្តល់សេវាបន្ថែម,

៦) កម្រៃផ្សេងទៀតដែលត្រូវកំណត់ដោយ ក.ប.ទ. បន្ទាប់ពីបានផ្តល់ឱកាសវេលាសម្រាប់អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណ និង អ្នកពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ផ្តល់មតិតាមរយៈការពិគ្រោះយោបល់សាធារណៈ ។

ខ) ក.ប.ទ. ត្រូវកំណត់កម្រៃឱ្យសមស្រប ឆ្លើយតបទៅនឹងថ្លៃដើម អាចអនុវត្ត និង ដោយពុំរើសអើងចំពោះអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍នៅក្នុងប្រភេទដូចគ្នា បន្ទាប់ពីបានផ្តល់ឱកាសវេលាគ្រប់គ្រាន់សម្រាប់អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ និង បុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ផ្តល់មតិតាមរយៈការពិគ្រោះយោបល់សាធារណៈ ។

គ ) ក.ប.ទ. មានសិទ្ធិលើកលែងការបង់កម្រៃផ្នែកខ្លះរបស់អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ និង បុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយចំនួន ។ ការលើកលែងនេះ ត្រូវមានសុភនិច្ឆ័យត្រឹមត្រូវប្រកបដោយតម្លាភាព បន្ទាប់ពីបានផ្តល់ដំណឹង និង ផ្តល់ឱកាសវេលាគ្រប់គ្រាន់សម្រាប់អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ និង បុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ផ្តល់មតិតាមរយៈការពិគ្រោះយោបល់សាធារណៈ ។

**ប្រការ ២៤.-**

ការបង់កម្រៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ និង កម្រៃពាក់ព័ន្ធ ពុំអាចយឺតយ៉ាវ ឬ ខកខានបានឡើយ ។ អ្នកកាន់ ឬ អ្នកទទួលលិខិត

អនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ត្រូវពន្យល់អំពីមូលហេតុ ឬ បង្ហាញព័ត៌មានដែលបណ្តាលឱ្យយឺតយ៉ាវ ឬ ខកខាន ។ ពុំនោះសោត អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ត្រូវ ៖

ក) បង់ការប្រាក់ពិន័យដោយមានប្រតិសកម្មទៅនឹងកាលបរិច្ឆេទកំណត់ការទូទាត់តាមអត្រាដែលកំណត់ដោយ ក.ប.ទ. ផ្អែកលើអត្រាការប្រាក់កម្ចីរបស់ធនាគារជាតិនៃកម្ពុជា ចំពោះការយឺតយ៉ាវ ឬ ខកខានបង់កម្រៃក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃកាលបរិច្ឆេទកំណត់ការទូទាត់ ។

ខ) រងការអនុវត្តប្រការ ៣៣ នៃប្រកាសនេះ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតដោយរាប់បញ្ចូលទាំងការព្យួរអាជ្ញាបណ្ណ ឬ ការផ្អាកសេវាទូរគមនាគមន៍ពាក់ព័ន្ធចំពោះការយឺតយ៉ាវ ឬ ខកខានដោយចេតនា ឬ ដដែលៗ ក្នុងការបង់កម្រៃរយៈពេល ៣០ (សាបសិប) ថ្ងៃនៃកាលបរិច្ឆេទកំណត់នៃការទូទាត់ ។

**ប្រការ ២៥.-**

ន.ទ.ក. មានសិទ្ធិចេញសេចក្តីជូនដំណឹង សេចក្តីណែនាំ សេចក្តីសម្រេច និង កំណត់នីតិវិធីអនុវត្តប្រកាសនេះ ឬ ផ្តល់ការណែនាំអំពីការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ទាក់ទងនឹងសកម្មភាពដែលពុំគ្របដណ្តប់ដោយបទប្បញ្ញត្តិដទៃទៀត ។

ការអនុវត្តសិទ្ធិនេះ ត្រូវ ៖

ក) ផ្តល់ដំណឹងមុនរយៈពេល ៣០ (សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ និង ផ្តល់ឱកាសវេលាគ្រប់គ្រាន់សម្រាប់អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ព្រមទាំងអ្នកប្រើប្រាស់ផ្តល់មតិតាមរយៈការពិគ្រោះយោបល់សាធារណៈអំពីការប៉ះពាល់ដែលអាចកើតឡើងតាមយថាហេតុ ។

ខ) ពន្យល់ និង បង្ហាញច្បាស់លាស់អំពីមូលដ្ឋាននានា និង ផ្សព្វផ្សាយសាធារណៈនៅលើគេហទំព័រ ។

## ជំពូកទី ៦
## សិទ្ធិ និង ភាតព្វកិច្ចដោយឡែក
## របស់អ្នកទទួលអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍

**ប្រការ ២៦.-**

អនុលោមតាមច្បាប់ស្តីពីទូរគមនាគមន៍ ច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត ពិសេសបទប្បញ្ញត្តិស្តីពីការប្រកួតប្រជែង និង បទប្បញ្ញត្តិស្តីពីការតភ្ជាប់បណ្តាញទូរគមនា-គមន៍ ព្រមទាំងការពិនិត្យវាយតម្លៃអំពីឧត្តមភាពលើទីផ្សារទូរគមនាគមន៍ ន.ទ.ក. អាចកំណត់កាតព្វកិច្ចដោយឡែកចំពោះអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ។ ការកំណត់កាតព្វកិច្ចដោយឡែកនេះអាចប្រព្រឹត្តទៅបានតាមរយៈការកែប្រែ ឬ បំពេញបន្ថែមលក្ខខណ្ឌនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ស្របតាមប្រការ ១៩ នៃប្រកាសនេះ។

**ប្រការ ២៧.-**

នៅពេលទទួលអាជ្ញាបណ្ណថ្មីគ្រប់ប្រភេទ អ្នកដាក់ពាក្យស្នើសុំត្រូវតម្កល់ប្រាក់កក់សម្រាប់ធានាលើការអនុវត្តគម្រោងនិងកាតព្វកិច្ចចែងក្នុងអាជ្ញាបណ្ណ រួមមានការគ្របដណ្តប់តំបន់សេវា ការស្ថាបនាបណ្តាញ ការដាក់ឱ្យដំណើរការ និង គុណភាពសេវា ឬ ក្របខណ្ឌគតិយុត្តជរមាន។ ប្រាក់កក់នេះត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក.ប.ទ. ។

ន.ទ.ក. ត្រូវប្រគល់ប្រាក់កក់ទៅឱ្យអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណ វិញ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីគម្រោងនិងកាតព្វកិច្ចចែងក្នុងអាជ្ញាបណ្ណបានៈ

- អនុវត្ត ៣០ (សាមសិប) ភាគរយចំពោះអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា និងអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់។
- បញ្ចប់ការស្ថាបនាប្រព័ន្ធ និងដាក់ឱ្យដំណើរការសេវា ១០០ (មួយរយ) ភាគរយចំពោះអាជ្ញាបណ្ណសេវាទូរគមនាគមន៍ ។

ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ ប្រសិនបើអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណខកខានពុំអនុ-វត្តគម្រោង ឬ មិនគោរពតាមកាតព្វកិច្ចដូចចែងក្នុងអាជ្ញាបណ្ណ ឬ ក្របខណ្ឌគតិយុត្តជរមាន ដោយរាប់បញ្ចូលទាំងការខកខានពុំបង់កម្រៃពិន័យទាន់ពេលវេលា ន.ទ.ក. នឹងចាត់វិធានការដកហូតប្រាក់កក់ជានាបង់ចូលថវិការដ្ឋតាមនីតិវិធី ។

**ប្រការ ២៨.-**

អនុលោមតាមផ្នែកទី១ ជំពូក៩ នៃច្បាប់ស្តីពីទូរគមនាគមន៍ មុននឹងប្រើប្រាស់ដីធ្លីជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬ ទ្រព្យសម្បត្តិឯកជន

សម្រាប់សាងសង់ ដំឡើង ថែរក្សា ជួសជុលហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ឬ ប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណគ្រប់ប្រភេទ ត្រូវ៖

ក) ចរចា និង ចុះកិច្ចព្រមព្រៀងជាមួយកម្មសិទ្ធិករស្របតាមច្បាប់ ។

ខ) សុំអនុញ្ញាត និង/ឬ សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ឬ កម្មសិទ្ធិករ ។

**ប្រការ ២៩.-**

នៅពេលសាងសង់បណ្ដាញក្រោមដី លើដី ឬ លើអាកាសនៅតាមទីសាធារណៈ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណគ្រប់ប្រភេទ ត្រូវមានវិធានការបញ្ចៀស ៖

ក ) ការប៉ះពាល់បរិស្ថាន សង្គម វប្បធម៌ និង ធម្មជាតិ ព្រមទាំងសកម្មភាពទាំងឡាយណាដែលប្រព្រឹត្តផ្ទុយច្បាប់ និង បទប្បញ្ញត្តិផ្សេងទៀត ។

ខ) គ្រោះថ្នាក់ចំពោះមនុស្ស ឬ ការបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ។

គ) ការកកស្ទះចរាចរណ៍ផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក និង ផ្លូវអាកាស ។

ក្នុងករណី អ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណគ្រប់ប្រភេទ មិនបានអនុវត្តត្រឹមត្រូវតាមវិធានបញ្ចៀសដូចបានចែងក្នុងវាក្យខណ្ឌខាងលើ នៃប្រការនេះ ត្រូវទទួលទោស ស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ៣០.-**

អនុលោមតាមមាត្រា ៦៤ និង មាត្រា ៦៥ ជំពូកទី ១១ នៃច្បាប់ស្ដីពីទូរគមនាគមន៍ និង បទប្បញ្ញត្តិពាក់ព័ន្ធ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណប្រើប្រាស់លេខទូរគមនាគមន៍ស្របតាមផែនការប្លង់លេខទូរគមនាគមន៍មានសិទ្ធិ និង កាតព្វកិច្ចដូចតទៅ ៖

ក) បោះពុម្ពផ្សាយសៀវភៅរាយលេខទូរស័ព្ទ ឬ សៀវភៅអេឡិកត្រូនិកលេខទូរគមនាគមន៍ និង ផ្ដល់សេវាសៀវភៅស្វែងរកព័ត៌មានលេខទូរស័ព្ទ ។ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណត្រូវផ្ដល់ជូនអ្នកប្រើប្រាស់នូវជម្រើសដោយឥតគិតថ្លៃ ដើម្បីលើកលែងការរាប់បញ្ចូលនៅក្នុងសៀវភៅលេខទូរស័ព្ទ និង ស្វែងរកព័ត៌មានលេខទូរស័ព្ទ។

ខ) រក្សាទុកទិន្នន័យលេខទូរស័ព្ទរបស់អ្នកប្រើប្រាស់ដែលបានបំពេញទម្រង់បែបបទគ្រប់គ្រាន់ និង ត្រឹមត្រូវ ។

គ) រាប់បញ្ចូល និង កំណត់ឱ្យបានច្បាស់លាស់នូវលេខរបស់អ្នកប្រើប្រាស់ដែលបានសុំដកចេញពីសៀវភៅលេខទូរស័ព្ទ និង សៀវភៅស្វែងរកព័ត៌មានលេខទូរស័ព្ទ ។

ឃ) ពុំគិតថ្លៃការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ភ្ជាប់ទៅកាន់លេខគ្រាអាសន្នទាំងអស់ ដូចមានកំណត់នៅក្នុងផែនការប្លង់លេខទូរគមនាគមន៍ ។

ង) ធានាការអនុវត្តត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និង បំពេញសេចក្តីត្រូវការដទៃទៀតទាក់ទងនឹងការផ្តល់សេវាគ្រាអាសន្ន ស្របតាមការកំណត់របស់ ក.ប.ទ. តាមសំណើរបស់ ន.ទ.ក. ។

ច ) ចុះកិច្ចសន្យាស្តីអំពីលក្ខខណ្ឌនៃការផ្តល់ ការប្រើប្រាស់សេវាទូរគមនាគមន៍ និង លក្ខខណ្ឌចាំបាច់ដទៃទៀតជាមួយអ្នកប្រើប្រាស់ ។

ឆ) ផ្តល់ជូនឥតគិតថ្លៃចំពោះអ្នកប្រើប្រាស់របស់ខ្លួននូវ ៖

១) វិក្កយបត្រលម្អិតពេលទូទាត់ ចំពោះសេវាបង់ប្រាក់តាមក្រោយ,

២) ការត្រួតពិនិត្យតុល្យភាពទឹកប្រាក់នៅក្នុងគណនី ចំពោះសេវាបង់ប្រាក់ទុកមុន,

៣) រៀបចំនីតិវិធីដោះស្រាយវិវាទដោយយុត្តិធម៌ និង ប្រកបដោយតម្លាភាពជូនអ្នកប្រើប្រាស់,

៤) ការសាកសួរព័ត៌មានអំពីការផ្តល់សេវាតាមគ្រប់រូបភាព

៥) ផ្សព្វផ្សាយលក្ខខណ្ឌនៃការប្រើប្រាស់សេវាដោយរាប់បញ្ចូលទាំង អត្រាថ្លៃ និង គុណភាពសេវា,

៦) ធានារក្សាការសម្ងាត់នៃការសន្ទនា ការប្រើប្រាស់ និង ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ។

## ជំពូកទី ៧
## ការតាមដាន ត្រួតពិនិត្យ និង ការចាត់វិធានការ

**ប្រការ ៣១.-**

អនុលោមតាមចំណុច (ឈ) មាត្រា ១២ នៃច្បាប់ស្តីពីទូរគមនាគមន៍ និង ក្របខណ្ឌគតិយុត្តពាក់ព័ន្ធ ន.ទ.ក. ត្រូវ ៖

ក ) បង្កើតទម្រង់របាយការណ៍មួយសមស្រប បង្ហាញអំពីគ្រប់ប្រតិបត្តិការកំណត់នៅក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍សម្រាប់ឱ្យអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍បំពេញ និង ផ្ញើមកវិញតាមកាលបរិច្ឆេទកំណត់ ។

ខ ) សុំជាលាយលក្ខណ៍អក្សរទៅអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ឱ្យផ្តល់ព័ត៌មាន ទិន្នន័យ ឯកសារកិច្ចព្រម-

ព្រៀង កំណត់ត្រាប្រតិបត្តិការ និង ឯកសារចាំបាច់ដទៃទៀត ។ ការសុំនេះត្រូវសមហេតុសមផល និង ត្រូវផ្តល់ឱកាសយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការឱ្យអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍រៀបចំ និង បញ្ជូនការឆ្លើយតប លើកលែងតែមានការកំណត់តាមច្បាប់ ឬ បទប្បញ្ញត្តិដោយឡែក ។

ក្នុងករណី អ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណគ្រប់ប្រភេទ មិនបានអនុវត្តត្រឹមត្រូវតាមវិធានបញ្ចៀសដូចបានចែងក្នុងវាក្យខណ្ឌខាងលើនៃប្រការនេះ ត្រូវទទួលទោសស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ៣២.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ស្តីពីទូរគមនាគមន៍ និង មាត្រា ៣០ ជំពូកទី ៥ នៃអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ន.ទ.ក.លេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ខែមីនាឆ្នាំ២០១៦ ន.ទ.ក. ត្រូវបង្កើត និង រក្សាបញ្ជីលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដែលផ្តល់រួចហើយ ។ បញ្ជីនេះត្រូវចុះផ្សាយនៅលើគេហទំព័ររបស់ ន.ទ.ក. យ៉ាងហោចណាស់ត្រូវមានព័ត៌មានដូចតទៅ ៖

ក) នាមករណ៍ អាសយដ្ឋាន លេខទូរស័ព្ទ អ៊ីម៉ែល និង លេខទូរសាររបស់ក្រុមហ៊ុន,

ខ) លេខ កាលបរិច្ឆេទ និង សុពលភាពនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍,

គ) ប្រភេទនៃបណ្តាញ និង/ឬសេវាដែលអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍មានសិទ្ធិធ្វើប្រតិបត្តិការ ។

**ប្រការ ៣៣.-**

ការធ្វើអធិការកិច្ច ការអនុវត្តច្បាប់ ការដាក់ពាក្យបណ្តឹងតវ៉ា និង ការចាត់វិធានការលើការអនុវត្តលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ ត្រូវអនុលោមតាមមាត្រា ៧៤ មាត្រា ៧៥ ជំពូកទី ១៣ និង មាត្រា ៧៨ ជំពូកទី១៤ នៃច្បាប់ស្តីពីទូរគមនាគមន៍ ។

## ជំពូកទី ៨

## ការកែប្រែ ឬ បំពេញបន្ថែមលក្ខខណ្ឌនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណចាស់

**ប្រការ ៣៤.-**

អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ចាស់ គឺជារូបវន្តបុគ្គល ឬ នីតិបុគ្គលកំពុងកាន់កាប់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ដែលនៅមានសុពលភាព មុនច្បាប់ស្តីពីទូរគមនាគមន៍ និង ប្រកាសនេះចូលជាធរមាន ។

រាល់វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុដែលបានបែងចែកដោយ ន.ទ.ក. ទៅឱ្យអ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ចាស់ នឹងត្រូវកំណត់ដោយបទប្បញ្ញត្តិផ្សេងទៀតស្របតាមច្បាប់ស្តីពីទូរគមនាគមន៍ ។

ក) អនុលោមតាមមាត្រា ១១០ នៃច្បាប់ស្តីពីទូរគមនាគមន៍ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ ក្រោយពីច្បាប់នេះចូលជាធរមាន អ្នកកាន់ ឬ អ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ចាស់ ត្រូវដាក់ពាក្យ ឬ បំពេញទម្រង់បែបបទឡើងវិញសម្រាប់សុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណថ្មី។ បញ្ជីនៃប្រភេទអាជ្ញាបណ្ណចាស់ត្រូវកែប្រែ ឬ បំពេញបន្ថែមលក្ខខណ្ឌទៅជាអាជ្ញាបណ្ណថ្មី មានចែងនៅក្នុងប្រការ ៣៥ នៃប្រកាសនេះ។

ខ) ការដាក់ពាក្យស្នើសុំប្តូរលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណចាស់យកលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណថ្មី ត្រូវបង់កម្រៃនិយ័តកម្មប្រចាំឆ្នាំ កម្រៃដាក់ពាក្យស្នើសុំបន្ត ឬ ប្តូរថ្មី និង កម្រៃដទៃទៀត ដែលត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក.ប.ទ. និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

គ) សុពលភាពនៃអាជ្ញាបណ្ណថ្មី ត្រូវផ្តល់បន្តពីសុពលភាពដែលនៅសល់នៅក្នុងអាជ្ញាបណ្ណចាស់ ។ ប្រសិនបើអាជ្ញាបណ្ណចាស់មានលើសពីមួយ ត្រូវបញ្ចូលគ្នាទៅជាអាជ្ញាបណ្ណថ្មីតែមួយ ដោយកំណត់សុពលភាពលើមូលដ្ឋានសុពលភាពនៃអាជ្ញាបណ្ណចាស់ណាដែលនៅសល់យូរជាងគេ ។ អាជ្ញាបណ្ណថ្មី ត្រូវកំណត់លក្ខខណ្ឌដូចគ្នាសម្រាប់ប្រភេទអាជ្ញាបណ្ណនីមួយៗ ។ ន.ទ.ក. មានសិទ្ធិដាក់បញ្ចូលនៅក្នុងលក្ខខណ្ឌនៃអាជ្ញាបណ្ណថ្មីនូវគោលការណ៍ដែលកំណត់ដោយ ក.ប.ទ. ស្តីពីការដាក់កំហិតលក្ខខណ្ឌលើហេដ្ឋារចនាសម្ព័ន្ធ និង/ឬ សេវាទូរគមនាគមន៍មួយចំនួន ។

ឃ) ក្រោមវិសាលភាពនៃប្រកាសនេះ និង ស្របតាមខ្លឹមសារនៃចំណុច (ង) ខាងក្រោម បន្ទាប់ពីការពិគ្រោះយោបល់សាធារណៈត្រូវបានបញ្ចប់ និង ក្នុងរយៈពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពី ន.ទ.ក. ផ្សព្វផ្សាយជាសាធារណៈនូវទម្រង់បែបបទដាក់ពាក្យស្នើសុំថ្មី អ្នកកាន់ ឬអ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ

ឬអាជ្ញាបណ្ណចាស់ ត្រូវដាក់ពាក្យស្នើសុំប្តូរយកលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណថ្មី ។ ពុំនោះសោត លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណចាស់ត្រូវចាត់ជាមោឃៈដោយស្វ័យប្រវត្តិ ។

ង) អាជ្ញាបណ្ណចាស់ដែលពុំទាន់អស់សុពលភាពអាចបន្តប្រើប្រាស់បានក្រោមវិសាលភាពនៃច្បាប់ស្តីពីទូរគមនាគមន៍ និង ប្រកាសនេះ ប្រសិនបើ ៖

១) ន.ទ.ក. មិនទាន់ផ្តល់អាជ្ញាបណ្ណថ្មីជំនួសអាជ្ញាបណ្ណចាស់នោះ,

២) ក្នុងរយៈពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយសាធារណៈនូវសេចក្តីជូនដំណឹងស្តីអំពីការបំពេញទម្រង់បែបបទដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណថ្មី ។ ក្រោយរយៈពេលកំណត់នេះ លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ចាស់ពុំមានតម្លៃផ្លូវច្បាប់ឡើយ ទោះបីលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណថ្មីបាន ឬ ពុំបានផ្តល់ជូនក៏ដោយ ។

**ប្រការ ៣៥.-**

ប្រភេទអាជ្ញាបណ្ណថ្មីជំនួសអាជ្ញាបណ្ណចាស់ មានចែងក្នុងតារាងខាងក្រោម៖

| ល.រ. | ប្រភេទអាជ្ញាបណ្ណថ្មី | ប្រភេទអាជ្ញាបណ្ណចាស់ |
|---|---|---|
| ១ | ***ការស្ថាបនា ឬ/និង ការផ្តល់សេវាប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍*** | |
| | អាជ្ញាបណ្ណហេដ្ឋា-រចនាសម្ព័ន្ធនិងសេវា | - អាជ្ញាបណ្ណផ្តល់សេវាមាត់ច្រកទូរគមនាគមន៍អន្តរជាតិ,<br>- អាជ្ញាបណ្ណផ្តល់សេវាទូរស័ព្ទចល័ត ឬ អចល័ត,<br>- អាជ្ញាបណ្ណបណ្តាញខ្សែកាប្លិ៍និងស្ថានីយកាប្លិ៍ក្រោមបាតសមុទ្រ និង ផ្កាយរណប,<br>- អាជ្ញាបណ្ណកំណត់ទីតាំង និង តម្រង់ទិស,<br>(រួមបញ្ចូលហេដ្ឋារចនាសម្ព័ន្ធនិងសេវាទូរគមនាគមន៍ដែលត្រូវផ្តល់ក្រោមវិសាលភាពនៃអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ និង អាជ្ញាបណ្ណសេវា) ។ |
| | អាជ្ញាបណ្ណហេដ្ឋរចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ | - អាជ្ញាបណ្ណអង់តែនទូរគមនាគមន៍<br>- អាជ្ញាបណ្ណបណ្តាញខ្សែកាប្លិ៍អុបទិកលើគោក |
| ២ | ***ការផ្តល់សេវាទូរគមនាគមន៍*** | |

| | | |
|---|---|---|
| | អាជ្ញាបណ្ណសេវាទូរគមនាគមន៍ | - អាជ្ញាបណ្ណសេវា VoIP,<br>- អាជ្ញាបណ្ណផ្តល់សេវាអ៊ិនធឺណិត,<br>- អាជ្ញាបណ្ណសេវា Toll-Free,<br>- អាជ្ញាបណ្ណសេវា VSAT,<br>- អាជ្ញាបណ្ណតម្លៃបន្ថែម ។ |

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**ប្រការ ៣៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣៧.-**

នាយកខុទ្ទកាល័យ ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា អគ្គនាយករដ្ឋបាល អគ្គនាយកប្រៃសណីយ៍និងទូរគមនាគមន៍ អគ្គនាយកបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន អគ្គាធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត ប្រធានអង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវទទួល បន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

ត្រាំ អ៊ីវតឹក

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត

«ដើម្បីជូនជ្រាប»

- ដូចប្រការ ៣៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ ១ - សទ្ធានុក្រម**

ក) ***"ក្របខណ្ឌច្បាប់ជាធរមាន"*** *សំដៅដល់ច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិ/លិខិតបទដ្ឋានគតិយុត្តនានា ដែលចេញដោយរាជរដ្ឋាភិបាល ក.ប.ទ. ឬ ន.ទ.ក. ក្រោមវិសាលភាពនៃច្បាប់ស្តីពីទូរគមនាគមន៍ ។*

ខ) ***"សេវាទូរគមនាគមន៍"*** *សំដៅដល់សេវាទូរគមនាគមន៍ ដូចមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធទី ៤ ដែលត្រូវបានផ្តល់តាមរយៈបណ្តាញទូរគមនាគមន៍មួយ ឬ ច្រើន ។ សេវាទូរគមនាគមន៍នេះ មិនរួមបញ្ចូលសេវាដែលផ្តល់ទាំងស្រុងដោយអតិថិជន នៅក្រៅព្រំដែននៃផ្នែកបណ្តាញឡើយ ។*

គ) ***"លិខិតអនុញ្ញាត"*** *សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយ ន.ទ.ក. សម្រាប់ការធ្វើប្រតិបត្តិការដូចបានបញ្ជាក់ក្នុងមាត្រា ១៩ នៃច្បាប់ស្តីពីទូរគមនាគមន៍ ។*

ឃ) ***"វិញ្ញាបនបត្រ"*** *សំដៅដល់វិញ្ញាបនបត្រផ្តល់ដោយ ន.ទ.ក. សម្រាប់ការធ្វើប្រតិបត្តិការដូចបានបញ្ជាក់ក្នុងមាត្រា ១៦ នៃច្បាប់ស្តីពីទូរគមនាគមន៍។*

ង) ***"សិទ្ធិគ្រប់គ្រង"*** *សំដៅសិទ្ធិធ្វើជាម្ចាស់ដោយផ្ទាល់ ឬ មិនផ្ទាល់ដែលមានចំនួនលើសពីហាសិប (៥០) ភាគរយនៃភាគហ៊ុនអាចបោះឆ្នោត សិទ្ធិសមាជិក ឬ សិទ្ធិដៃគូទូទៅនៅក្នុងស្ថាប័នដទៃ ឬ ដែលអនុញ្ញាតឱ្យបុគ្គលមួយអាចអនុវត្តដូចខាងក្រោម៖*

១) *តែងតាំងក្រុមប្រឹក្សាភិបាល ឬ គណៈកម្មការដឹកនាំនៃស្ថាប័នដទៃ លើសពីហាសិប (៥០)ភាគរយ,*

២) *មានអំណាចក្នុងការដឹកនាំ គ្រប់គ្រង និងមានឥទ្ធិពលទៅលើសកម្មភាពសំខាន់ៗ ធ្វើការសម្រេចចិត្ត និង សកម្មភាពនៃស្ថាប័នដទៃ ទោះបីតាមរយៈលក្ខខណ្ឌនៃកិច្ចសន្យា ឬ មិនមែនក៏ដោយ ។*

ច) ***"ថ្ងៃ"*** *សំដៅដល់ថ្ងៃនៃប្រតិទិន រួមបញ្ចូលទាំងថ្ងៃចុងសប្តាហ៍ ។*

ឆ) ***"អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណមានឧត្តមភាពទីផ្សារ"*** *សំដៅដល់សហគ្រាស ឬក្រុមហ៊ុន ឬ ប្រតិបត្តិករទូរគមនាគមន៍ដែលធ្វើប្រតិបត្តិការដោយខ្លួនឯង ឬ សហការជាមួយភាគីដទៃដែលមានស្ថានភាពសេដ្ឋកិច្ចខ្លាំងក្លា និង មានលទ្ធភាពអាចប្រតិបត្តិការដោយឯករាជ្យ និង គ្របដណ្តប់លើដៃគូប្រកួតប្រជែង ព្រមទាំងអ្នកប្រើប្រាស់ ។*

ជ) ***"អ្នកប្រើប្រាស់"*** *សំដៅដល់បុគ្គល ឬ សាធារណជនដែលមិនមែនជាអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណ ជាអ្នកប្រើប្រាស់សេវាទូរគមនាគមន៍របស់អ្នកកាន់ ឬ អ្នកទទួលអ្នក*

អាជ្ញាបណ្ណ ។

ឈ) **"អាជ្ញាបណ្ណចាស់"** សំដៅដល់អាជ្ញាបណ្ណស្ថាបនា និង ប្រតិបត្តិការបណ្តាញទូរគមនាគមន៍ ឬ ផ្តល់សេវាទូរគមនាគមន៍ ដែលនៅមានសុពលភាពត្រឹមកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះ ។ អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណចាស់ សំដៅបុគ្គល ឬ នីតិបុគ្គលដែលកាន់កាប់ ឬត្រូវបានជ្រើសរើសឱ្យកាន់កាប់អាជ្ញា បណ្ណចាស់ទាំងនោះ ។

ញ) **"ព័ត៌មាន"** សំដៅទិន្នន័យ អក្សរ រូបភាព សំឡេង កូដ សញ្ញា ស៊ីញ៉ាល់ និងបណ្តុំនៃទិន្នន័យ ឬ បង្គុំនៃទិន្នន័យគ្រប់ប្រភេទ ។

ដ) **"សេវាមាត់ច្រកអន្តរជាតិ"** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធដែលអនុញ្ញាតឱ្យសេវាទូរគមនា-គមន៍ ( សំឡេង ទិន្នន័យ និង វីឌីអូ ) អាចបញ្ជូនរវាងបណ្តាញក្នុងស្រុក ឬក្នុងប្រទេស និង ប្រទេសដទៃ ។

ឋ) **បមាណីអាយភី** (Internet Protocol Exchange) សំដៅសណ្ឋាននៃការតភ្ជាប់បណ្តាញទូរគមនាគមន៍ សម្រាប់បមាណីកម្មនៃត្រាហ្វិកអាយភីរវាងអតិថិជនរបស់ប្រតិបត្តិករទូរស័ព្ទចល័ត និង អចល័តផ្សេងគ្នា ព្រមទាំងរវាងអ្នកផ្តល់សេវាប្រភេទផ្សេងទៀត ដូចជាក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតជាដើម ។

ឌ) **"អាជ្ញាបណ្ណ"** សំដៅដល់អាជ្ញាបណ្ណគ្រប់ប្រភេទចេញដោយ ន.ទ.ក. ស្របតាមមាត្រា ១៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលត្រូវបានបង្កើត និង ចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍ និង បទ-ប្បញ្ញត្តិពាក់ព័ន្ធ ។

ឍ) **"ប្រភេទនៃអាជ្ញាបណ្ណ"** សំដៅប្រភេទនៃអាជ្ញាបណ្ណនីមួយៗ រួមមានអាជ្ញាបណ្ណហេដ្ឋា-រចនាសម្ព័ន្ធនិងសេវា អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ និង អាជ្ញាបណ្ណសេវាទូរគមនាគមន៍ ។

ណ) **"អ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណ"** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល បានបង្កើត និង ចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកាន់កាប់ ឬ ទទួលអាជ្ញាបណ្ណ ។

ត) **"ក.ប.ទ."** សំដៅដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា ។

ថ) **"ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ"** សំដៅដល់ផ្នែក និង បណ្តុំនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលប្រើប្រាស់សម្រាប់ផ្តល់សេវាបណ្តាញហេដ្ឋារចនាសម្ព័ន្ធ ។

ទ) **"សេវាបណ្តាញហេដ្ឋារចនាសម្ព័ន្ធ"** សំដៅដល់សេវា (១) ជួល ឬ លក់បន្តទាំងស្រុង ឬ

ផ្នែកណាមួយនៃបណ្ដាញហេដ្ឋារចនាសម្ព័ន្ធដោយអ្នកទទួលអាជ្ញាបណ្ណឱ្យទៅអ្នកទទួលអាជ្ញាបណ្ណផ្សេងទៀត ឬ (២) ការផ្ដល់ដោយខ្លួនឯងនូវសេវាទូរគមនាគមន៍ តាមរយៈបណ្ដាញហេដ្ឋារចនាសម្ព័ន្ធ ។

ឍ) **"សេវាបណ្ដាញ"** សំដៅដល់សេវាសម្រាប់បញ្ជូន ឬ ទទួលព័ត៌មានដោយប្រើប្រាស់មធ្យោបាយគមនាគមន៍ រួមមានដូចជា អេឡិកត្រូម៉ាញ៉េទិក អគ្គិសនី វិទ្យុ ពន្លឺ ឬទម្រង់ដទៃ ។ សេវានេះមិនរួមបញ្ចូលសេវា ដែលផ្ដល់ទាំងស្រុងដោយអតិថិជន នៅក្រៅព្រំដែននៃផ្នែកបណ្ដាញឡើយ ។

ន) **"OTT"** សំដៅសេវាគ្រប់ប្រភេទដែលត្រូវបានផ្ដល់នៅលើអ៊ិនធឺណិត ដោយមិនបានផ្ដល់ដោយឆ្លងកាត់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្ដាញផ្ទាល់ខ្លួនរបស់អ្នកទទួលអាជ្ញាបណ្ណ ដែលរួមមានដូចជា កម្មវិធីជជែក ពាណិជ្ជកម្មអេឡិកត្រូនិក សេវាទាញយកវីឌេអូ និងសេវាសន្ទនានិងទូរស័ព្ទវីឌេអូ ។

ប) **"សេវាទូរគមនាគមន៍ឯកជន"** សំដៅសេវាទូរគមនាគមន៍ផ្ដល់ការតភ្ជាប់ពីចំណុចមួយទៅចំណុចមួយ ទៅកាន់អ្នកប្រើប្រាស់ចុងក្រោយ ឬ អ្នកទទួលអាជ្ញាបណ្ណដទៃ តែពុំត្រូវតភ្ជាប់ជាមួយបណ្ដាញបមាណីទូរគមនាគមន៍សាធារណៈទេ ។

ផ) **"បណ្ដាញបមាណីទូរគមនាគមន៍សាធារណៈ (PSTN)"** សំដៅដល់បណ្ដាញបមាណីទូរគមនាគមន៍ ក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ផ្ដល់សេវាទូរគមនាគមន៍សាធារណៈ ។

ព) **"ការចុះបញ្ជី"** សំដៅដល់ដំណើរការសុំអាជ្ញាបណ្ណសាមញ្ញ ប្រើប្រាស់សម្រាប់ទទួលអាជ្ញាបណ្ណសេវាទូរគមនាគមន៍ ។

ភ) **"ច្បាប់ស្ដីពីទូរគមនាគមន៍"** សំដៅដល់ច្បាប់ស្ដីពីទូរគមនាគមន៍ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ខែធ្នូឆ្នាំ២០១៥ ។

ម) **"បណ្ដាញទូរគមនាគមន៍"** សំដៅដល់បណ្ដាញហេដ្ឋារចនាសម្ព័ន្ធ គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ កុំព្យូទ័រ ឧបករណ៍ដែលមានមុខងារដូចទៅនឹងកុំព្យូទ័រ និងសម្ភារៈពាក់ព័ន្ធ ដែលប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍មាន ឬ អត់ខ្សែ ។

**ឧបសម្ព័ន្ធ ២ - ទម្រង់បែបបទ និង ព័ត៌មានតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំលិខិត-អនុញ្ញាត**

**ក)    *លិខិតអនុញ្ញាតការនាំចូល ការនាំចេញ ការផ្គត់ផ្គង់ និង ការចែកចាយគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍៖***

*ក្នុងករណី អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតការនាំចូល ការនាំចេញ ការផ្គត់ផ្គង់ និង ការចែកចាយគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ ត្រូវបំពេញទម្រង់បែបបទ ដូចតទៅ៖*

*ក.១) សម្រាប់បម្រើឱ្យប្រតិបត្តិការផ្ទាល់៖*

**ក.១.១) ចំពោះនីតិបុគ្គលសាធារណៈ ៖**

- *ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖*
    - *វិក្កយបត្រ* (Invoice)..........................................................០១ ច្បាប់
    - *បញ្ជីវេចខ្ចប់* (Parking List)...................................................០១ ច្បាប់
    - *ឯកសារដឹកជញ្ជូន* (Airway Bill / Bill of Landing)......................០១ ច្បាប់
    - *ឯកសារបញ្ជាក់ពីលក្ខណៈបច្ចេកទេស*...................................០១ ច្បាប់

**ក.១.២) ចំពោះនីតិបុគ្គលឯកជន៖**

- *ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖*
    - *ច្បាប់ចម្លងលិខិតបញ្ជាក់ការចុះបញ្ជីបើកក្រុមហ៊ុនពីក្រសួងពាណិជ្ជកម្ម ឬ លិខិតទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ដោយមានលក្ខខណ្ឌ*.......................................................................០១ ច្បាប់
    - *ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម*..........................០១ ច្បាប់
    - *ច្បាប់ចម្លងបណ្ណប៉ាតង់*.........................................................០១ ច្បាប់
    - *វិក្កយបត្រ* (Invoice)..........................................................០១ ច្បាប់
    - *បញ្ជីវេចខ្ចប់* (Parking List)...................................................០១ ច្បាប់
    - *ឯកសារដឹកជញ្ជូន* (Airway Bill / Bill of Landing)......................០១ ច្បាប់
    - *ឯកសារបញ្ជាក់ពីលក្ខណៈបច្ចេកទេស*...................................០១ ច្បាប់

**ក.១.៣) ចំពោះរូបវន្តបុគ្គល៖**

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
    - ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ បណ្ណគ្រួសារ ឬ លិខិតឆ្លងដែនមានសុពលភាព........................................................................០១ ច្បាប់
    - ចំនួនបរិក្ខារមិនលើសពី ០២ (ពីរ) កំប្លេ
    - វិក្កយបត្រ (Invoice).........................................................................០១ ច្បាប់
    - បញ្ជីវេចខ្ចប់ (Parking List)..................................................០១ ច្បាប់
    - ឯកសារដឹកជញ្ជូន (Airway Bill / Bill of Landing)......................០១ ច្បាប់
    - ឯកសារបញ្ជាក់ពីលក្ខណៈបច្ចេកទេស..................................០១ ច្បាប់

**ក.១.៤) ចំពោះអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណទូរគមនាគមន៍ ដែលទទួលបានការអនុញ្ញាតពន្ធជាបន្ទុករបស់រដ្ឋ ស្របតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា៖**

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
    - ច្បាប់ចម្លងលិខិតបញ្ជាក់ទទួលស្គាល់ជាក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដែលបានធ្វើនិត្យានុកូលកម្ម.........................០១ ច្បាប់
    - ច្បាប់ចម្លងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍...................០១ ច្បាប់
    - ច្បាប់ចម្លងវិក្កយបត្រប្រាក់កក់ធានាប្រតិបត្តិការអាជ្ញាបណ្ណ....០១ ច្បាប់
    - បញ្ជីគោលរាយមុខគ្រឿងសម្ភារៈបរិក្ខារនាំចូល.....................០៦ ច្បាប់
    - បញ្ជីកាត់ស្តុកនាំចូល (ក្នុងករណីស្នើសុំបន្ត)............................០៦ ច្បាប់

**ខ) លិខិតអនុញ្ញាតស្តីពីការបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិតកាហ្វេ៖**

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត (ថ្មី ឬ បន្ត) ត្រូវបំពេញទម្រង់បែបបទដូចតទៅ៖

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
    - ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ បណ្ណគ្រួសារ ឬ លិខិតឆ្លងដែនមានសុពលភាព........................................................................០១ ច្បាប់

- លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងសាល ឬ កិច្ចសន្យាជួលទីតាំងមានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណីជួលទីតាំង).............................................................០១ ច្បាប់

- អ្នកដាក់ពាក្យស្នើសុំបន្តអាជីវកម្ម ឬ បន្តលិខិតអនុញ្ញាត ត្រូវដាក់ពាក្យស្នើសុំមក ន.ទ.ក. ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃ មុននឹងលិខិតអនុញ្ញាតអស់សុពលភាព។

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត (ផ្លាស់ប្តូរអាសយដ្ឋានសាល) ត្រូវបំពេញទម្រង់បែបបទ ដូចតទៅ៖

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
  - ច្បាប់ចម្លងស្តីពីការបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិតកាហ្វេចាស់ ដែលផ្តល់ដោយ ន.ទ.ក..............................................០១ ច្បាប់
  - លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងសាលថ្មី ឬ កិច្ចសន្យាជួលទីតាំងថ្មីមានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណីជួលទីតាំងថ្មី)...........................................................០១ ច្បាប់
- អ្នកដាក់ពាក្យស្នើសុំបន្តអាជីវកម្ម ឬ បន្តលិខិតអនុញ្ញាត ត្រូវដាក់ពាក្យស្នើសុំមក ន.ទ.ក. ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃ មុននឹងលិខិតអនុញ្ញាតអស់សុពលភាព។

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំលុបលិខិតអនុញ្ញាត (បិទអាជីវកម្ម) ត្រូវបំពេញទម្រង់បែបបទ ដូចតទៅ៖

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
- ច្បាប់ចម្លងស្តីពីការបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិតកាហ្វេចាស់ ដែលផ្តល់ដោយ ន.ទ.ក...................................................................០១ ច្បាប់
- ច្បាប់ចម្លងលិខិតបញ្ជាក់ការបង់កម្រៃតាមការកំណត់.........................០១ ច្បាប់
- អ្នកដាក់ពាក្យស្នើសុំបិទអាជីវកម្ម ឬ លុបលិខិតអនុញ្ញាត ត្រូវដាក់ពាក្យស្នើសុំមក ន.ទ.ក. ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃ មុននឹងលិខិតអនុញ្ញាតអស់សុពលភាព។

ចំពោះការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្តូរនាមករណ៍ម្ចាស់សាល មិនត្រូវបាន

អនុញ្ញាតឡើយ គឺតម្រូវឱ្យដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតថ្មី។

**គ) លិខិតអនុញ្ញាតការបើកលក់ និង/ឬ ជួសជុលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍៖**

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតការបើកលក់ និង/ឬ ជួសជុលគ្រឿងបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ (ថ្មី ឬ បន្ត) ត្រូវបំពេញទម្រង់បែបបទ ដូចតទៅ៖

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
  - ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ បណ្ណគ្រួសារ ឬ លិខិតឆ្លងដែនមានសុពលភាព..........................................................................០១ ច្បាប់
  - ច្បាប់ចម្លងបណ្ណប៉ាតង់..........................................................០១ ច្បាប់
  - លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងលក់និង/ឬជួសជុល ឬ កិច្ចសន្យាជួលទីតាំងលក់និង/ឬជួសជុល មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណីជួលទីតាំង)................០១ ច្បាប់
- អ្នកដាក់ពាក្យស្នើសុំបន្តអាជីវកម្ម ឬ បន្តលិខិតអនុញ្ញាត ឬផ្ទេរទីតាំង ត្រូវដាក់ពាក្យស្នើសុំមក ន.ទ.ក. ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃ មុននឹងលិខិតអនុញ្ញាតអស់សុពលភាព។

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតការនាំចូល លក់ និង/ឬ ជួសជុលគ្រឿងបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ (ថ្មី ឬ បន្ត) ត្រូវបំពេញទម្រង់បែបបទ ដូចតទៅ៖

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
  - ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ បណ្ណគ្រួសារ ឬ លិខិតឆ្លងដែនមានសុពលភាព..........................................................................០១ ច្បាប់
  - ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម មានសុពលភាព.០១ ច្បាប់
  - ច្បាប់ចម្លងបណ្ណប៉ាតង់ (របបស្វ័យប្រកាស) មានសុពលភាព..០១ ច្បាប់
  - លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងបើកការនាំចូល លក់និង/ឬជួសជុល ឬ កិច្ចសន្យាជួលទីតាំងបើកការនាំចូល លក់និង/ឬជួសជុល មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណី

ជួលទីតាំង)..........................................................................០១ ច្បាប់

- អ្នកដាក់ពាក្យស្នើសុំបន្តអាជីវកម្ម ឬ បន្តលិខិតអនុញ្ញាត ឬផ្ទេរទីតាំង ត្រូវដាក់ពាក្យស្នើសុំមក ន.ទ.ក. ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃ មុននឹងលិខិតអនុញ្ញាតអស់សុពលភាព។

**ឃ) លិខិតអនុញ្ញាតការបោះពុម្ពផ្សាយសៀវភៅលេខទូរគមនាគមន៍ ៖**

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតការបោះពុម្ពផ្សាយសៀវភៅលេខ-ទូរគមនាគមន៍ (ថ្មី ឬ បន្ត) ត្រូវបំពេញទម្រង់បែបបទដូចតទៅ៖

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
    - ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ បណ្ណគ្រួសារ ឬ លិខិតឆ្លងដែនមានសុពលភាព..........................................................................០១ ច្បាប់
    - ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម មានសុពលភាព.០១ ច្បាប់
    - ច្បាប់ចម្លងបណ្ណប៉ាតង់ (របបស្វ័យប្រកាស) មានសុពលភាព..០១ ច្បាប់
    - លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងបើកការបោះពុម្ពសៀវភៅ ឬ កិច្ចសន្យាជួលទីតាំងបើកការបោះពុម្ពសៀវភៅ មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណីជួលទីតាំង) ..........................................................................០១ ច្បាប់
- អ្នកដាក់ពាក្យស្នើសុំបន្តអាជីវកម្ម ឬ បន្តលិខិតអនុញ្ញាត ឬផ្ទេរទីតាំង ត្រូវដាក់ពាក្យស្នើសុំមក ន.ទ.ក. ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃ មុននឹងលិខិតអនុញ្ញាតអស់សុពលភាព។

## ង) គំនូសបំព្រួញនៃចរន្តពិនិត្យពាក្យស្នើសុំលិខិតអនុញ្ញាត



**ឧបសម្ព័ន្ធ ៣ - ទម្រង់បែបបទ និង ព័ត៌មានតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ**

**ក) *វិញ្ញាបនបត្រស្ដីពីការទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និង ចែកចាយគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍៖***

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រស្ដីពីការទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និង ចែកចាយគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ ត្រូវបំពេញទម្រង់បែបបទ ដូចតទៅ៖

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
  - ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ បណ្ណគ្រួសារ ឬ លិខិតឆ្លងដែនមានសុពលភាព........................................................................០១ ច្បាប់
  - ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម មានសុពលភាព.០១ ច្បាប់
  - ច្បាប់ចម្លងបណ្ណប៉ាតង់ (របបស្វ័យប្រកាស) មានសុពលភាព..០១ ច្បាប់
  - លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងបើកអាជីវកម្ម ឬ កិច្ចសន្យាជួលទីតាំងបើកអាជីវកម្ម មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណីជួលទីតាំង)................................០១ ច្បាប់
- អ្នកដាក់ពាក្យស្នើសុំបន្តអាជីវកម្ម ឬ បន្តលិខិតអនុញ្ញាត ឬផ្ទេរទីតាំង ត្រូវដាក់ពាក្យស្នើសុំមក ន.ទ.ក. ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃ មុននឹងវិញ្ញាបនបត្រអស់សុពលភាព។

**ខ) *វិញ្ញាបនបត្រស្ដីពីការទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍៖***

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រស្ដីពីការទទួលស្គាល់យថាប្រភេទគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ (ថ្មី ឬ បន្ត) ត្រូវបំពេញទម្រង់បែបបទដូចតទៅ៖

- ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖
  - ច្បាប់ចម្លងវិញ្ញាបនបត្រស្ដីពីការទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល

និង ចែកចាយគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង វិទ្យុគមនាគមន៍ ..........................................................................................០១ ច្បាប់

- ច្បាប់ចម្លងអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ (ចំពោះតែអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណទូរគមនាគមន៍ ពី ន.ទ.ក. ប៉ុណ្ណោះ)........០១ ច្បាប់
- ឯកសារបញ្ជាក់ពីលក្ខណៈបច្ចេកទេស.................................០១ ច្បាប់
- របាយការណ៍ពិសោធន៍គុណភាពនៃគ្រឿងសម្ភារៈបរិក្ខារ.......០១ ច្បាប់

- អ្នកដាក់ពាក្យស្នើសុំបន្តអាជីវកម្ម ឬ បន្តវិញ្ញាបនបត្រ ត្រូវដាក់ពាក្យស្នើសុំមក ន.ទ.ក. ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃ មុននឹងវិញ្ញាបនបត្រអស់សុពលភាព។

## គ) គំនូសបំប្រួញនៃចរន្តពិនិត្យពាក្យស្នើសុំវិញ្ញាបនបត្រ



**ឧបសម្ព័ន្ធ ៤ - ទម្រង់បែបបទ និង ព័ត៌មានតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍**

## ក) អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា៖

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា ត្រូវដាក់លិខិតស្នើសុំ និងទម្រង់ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មមានសុពលភាព..................០១ ច្បាប់
- ច្បាប់ចម្លងលក្ខន្តិកៈចុះបញ្ជីពាណិជ្ជកម្ម...............................................០១ ច្បាប់
- ច្បាប់ចម្លងបណ្ណប៉ាតង់ (របបស្វ័យប្រកាស) មានសុពលភាព..................០១ ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនមានសុពលភាព............០១ ច្បាប់
- លិខិតបញ្ជាក់ទទួលស្គាល់ជាក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) (ប្រសិនមាន).......................................................................................................០១ ច្បាប់
- ផែនការបច្ចេកទេស...................................................................................០១ ច្បាប់
- ផែនការធុរកិច្ច........................................................................................០១ ច្បាប់
- ផែនការហិរញ្ញវត្ថុ.....................................................................................០១ ច្បាប់
- របាយការណ៍គណនេយ្យដែលត្រូវបានធ្វើសវនកម្ម (៥ឆ្នាំចុងក្រោយ).....០១ ច្បាប់

អ្នកស្នើសុំអាជ្ញាបណ្ណត្រូវផ្តល់ព័ត៌មានតម្រូវភ្ជាប់ជាមួយទម្រង់ពាក្យស្នើសុំដូចខាងក្រោម៖

- **ព័ត៌មានទូទៅ**៖ ឈ្មោះស្ថាប័ន/ក្រុមហ៊ុន, អាសយដ្ឋានទំនាក់ទំនង, លេខវិញ្ញាបនបត្រចុះបញ្ជី, អាសយដ្ឋានចុះបញ្ជី, កាលបរិច្ឆេទចុះបញ្ជី, ទីកន្លែងចុះបញ្ជី, និង ព័តមានអ្នកទំនាក់ទំនងសម្រាប់ការស្នើសុំអាជ្ញាបណ្ណ ។
- **ព័ត៌មានអំពីអភិបាល និង ម្ចាស់ក្រុមហ៊ុន**៖ ឈ្មោះក្រុមហ៊ុនមេ (ប្រសិនមាន), អត្តសញ្ញាណនៃអភិបាលក្រុមហ៊ុន, អត្តសញ្ញាណនៃម្ចាស់ហ៊ុន, និង អ្នកទទួល ឬ អ្នកកាន់អាជ្ញាបណ្ណដទៃដែលមានភាគហ៊ុនក្នុងក្រុមហ៊ុនកំពុងស្នើសុំអាជ្ញាបណ្ណ ។
- **ព័ត៌មានប្រតិបត្តិការទូរគមនាគមន៍បច្ចុប្បន្ន (ករណីអ្នកស្នើកំពុងកាន់កាប់អាជ្ញាបណ្ណផ្សេង)**៖ ប្រភេទអាជ្ញាបណ្ណ, លេខអាជ្ញាបណ្ណ, កាលបរិច្ឆេទអាជ្ញាបណ្ណ, កាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាបណ្ណ, បណ្តាញនិង/ឬសេវាដែលផ្តល់ក្រោមសុពលភាពនៃអាជ្ញាបណ្ណបច្ចុប្បន្ន ។

- ***ព័ត៌មានហេដ្ឋារចនាសម្ព័ន្ធត្រូវស្ថាបនា និងសេវាត្រូវផ្តល់៖*** ប្រភេទហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍, រូបសណ្ឋានបណ្តាញ, បច្ចេកវិទ្យាដែលត្រូវប្រើប្រាស់, ប្រភេទសេវាទូរគមនាគមន៍, យុទ្ធសាស្ត្រធុរកិច្ច កាលបរិច្ឆេទដែលគ្រោងចាប់ផ្តើមប្រតិបត្តិការ, ខេត្ត/ក្រុងដែលគ្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និង/ឬ សេវាក្នុងរយៈពេល ៥ ឆ្នាំ, និង អតិថិជនគ្រោងទុកដែលនឹងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិង/ឬសេវា ។
- ***ព័ត៌មានហិរញ្ញវត្ថុ៖*** ប្រភពនៃការស្នើសុំទុន និង ចំនួនទឹកប្រាក់ដែលទទួលពីប្រភពនីមួយៗ, កាលបរិច្ឆេទបានទទួលទុន, លិខិតធានា និងឯកសារពាក់ព័ន្ធធានាអំពីការបានទទួលទុន ។

**ខ) អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់៖**

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ត្រូវដាក់លិខិតស្នើសុំ និងទម្រង់ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មមានសុពលភាព..................០១ ច្បាប់
- ច្បាប់ចម្លងលក្ខន្តិកៈចុះបញ្ជីពាណិជ្ជកម្ម..............................................០១ ច្បាប់
- ច្បាប់ចម្លងបណ្ណប៉ាតង់ (របបស្វ័យប្រកាស) មានសុពលភាព..................០១ ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនមានសុពលភាព............០១ ច្បាប់
- លិខិតបញ្ជាក់ទទួលស្គាល់ជាក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) (ប្រសិនមាន)....................................................................................................០១ ច្បាប់
- ផែនការបច្ចេកទេស.............................................................................០១ ច្បាប់
- ផែនការធុរកិច្ច....................................................................................០១ ច្បាប់
- ផែនការហិរញ្ញវត្ថុ................................................................................០១ ច្បាប់
- របាយការណ៍គណនេយ្យដែលត្រូវបានធ្វើសវនកម្ម.............................០១ ច្បាប់

អ្នកស្នើសុំអាជ្ញាបណ្ណត្រូវផ្តល់ព័ត៌មានតម្រូវភ្ជាប់ជាមួយទម្រង់ពាក្យស្នើសុំដូចខាងក្រោម៖

- ***ព័ត៌មានទូទៅ៖*** ឈ្មោះស្ថាប័ន/ក្រុមហ៊ុន, អាសយដ្ឋានទំនាក់ទំនង, លេខវិញ្ញាបនបត្រចុះបញ្ជី, អាសយដ្ឋានចុះបញ្ជី, កាលបរិច្ឆេទចុះបញ្ជី, ទីកន្លែងចុះបញ្ជី, និង ព័ត៌មានអ្នកទំនាក់ទំនងសម្រាប់ការស្នើសុំអាជ្ញាបណ្ណ ។
- ***ព័ត៌មានអំពីអភិបាល និង ម្ចាស់ក្រុមហ៊ុន៖*** ឈ្មោះក្រុមហ៊ុនមេ (ប្រសិនមាន), អត្ត-

សញ្ញាណនៃអភិបាលក្រុមហ៊ុន, អត្តសញ្ញាណនៃម្ចាស់ហ៊ុន, និង អ្នកទទួល ឬ អ្នកកាន់អាជ្ញាបណ្ណដទៃដែលមានភាគហ៊ុនក្នុងក្រុមហ៊ុនកំពុងស្នើសុំអាជ្ញាបណ្ណ ។

- **ព័ត៌មានប្រតិបត្តិការទូរគមនាគមន៍បច្ចុប្បន្ន (ករណីអ្នកស្នើកំពុងកាន់កាប់អាជ្ញាបណ្ណផ្សេង)**៖ ប្រភេទអាជ្ញាបណ្ណ, លេខអាជ្ញាបណ្ណ, កាលបរិច្ឆេទអាជ្ញាបណ្ណ, កាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាបណ្ណ, បណ្ដាញនិង/ឬសេវាដែលផ្ដល់ក្រោមវិសាលភាពនៃអាជ្ញាបណ្ណបច្ចុប្បន្ន ។
- **ព័ត៌មានហេដ្ឋារចនាសម្ព័ន្ធត្រូវស្ថាបនា និងសេវាត្រូវផ្ដល់**៖ ប្រភេទហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍, រូបសណ្ឋានបណ្ដាញ, បច្ចេកវិទ្យាដែលត្រូវប្រើប្រាស់, ប្រភេទសេវាទូរគមនាគមន៍, យុទ្ធសាស្ត្រធុរកិច្ច កាលបរិច្ឆេទដែលគ្រោងចាប់ផ្ដើមប្រតិបត្តិការ, ខេត្ត/ក្រុងដែលគ្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និង/ឬ សេវាក្នុងរយៈពេល ៥ ឆ្នាំ, និង អតិថិជនគ្រោងទុកដែលនឹងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិង/ឬសេវា ។
- **ព័ត៌មានហិរញ្ញវត្ថុ**៖ ប្រភពនៃការស្នើសុំទុន និង ចំនួនទឹកប្រាក់ដែលទទួលពីប្រភពនីមួយៗ, កាលបរិច្ឆេទបានទទួលទុន, លិខិតធានា និងឯកសារពាក់ព័ន្ធធានាអំពីការបានទទួលទុន ។

**គ) អាជ្ញាបណ្ណសេវាទូរគមនាគមន៍៖**

ក្នុងករណី អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសេវាទូរគមនាគមន៍ ត្រូវដាក់លិខិតស្នើសុំ និងទម្រង់ពាក្យស្នើសុំដែលត្រូវកំណត់ជាទម្រង់គំរូដោយ ន.ទ.ក. ដោយភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មមានសុពលភាព.......................០១ ច្បាប់
- ច្បាប់ចម្លងលក្ខន្តិកៈចុះបញ្ជីពាណិជ្ជកម្ម.................................................០១ ច្បាប់
- ច្បាប់ចម្លងបណ្ណប៉ាតង់ (របបស្វ័យប្រកាស) មានសុពលភាព......................០១ ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនមានសុពលភាព...............០១ ច្បាប់
- ផែនការបច្ចេកទេស.................................................................................០១ ច្បាប់
- ផែនការធុរកិច្ច.......................................................................................០១ ច្បាប់

អ្នកស្នើសុំអាជ្ញាបណ្ណត្រូវផ្ដល់ព័ត៌មានតម្រូវភ្ជាប់ជាមួយទម្រង់ពាក្យស្នើសុំដូចខាងក្រោម៖

- **ព័ត៌មានទូទៅ**៖ ឈ្មោះស្ថាប័ន/ក្រុមហ៊ុន, អាសយដ្ឋានទំនាក់ទំនង, លេខវិញ្ញាបនបត្រចុះបញ្ជី, អាសយដ្ឋានចុះបញ្ជី, កាលបរិច្ឆេទចុះបញ្ជី, ទីកន្លែងចុះបញ្ជី, និង ព័ត៌មាន

អ្នកទំនាក់ទំនងសម្រាប់ការស្នើសុំអាជ្ញាបណ្ណ ។

- ***<u>ព័ត៌មានអំពីអភិបាល និង ម្ចាស់ក្រុមហ៊ុន</u>៖*** ឈ្មោះក្រុមហ៊ុនមេ (ប្រសិនមាន), អត្តសញ្ញាណនៃអភិបាលក្រុមហ៊ុន, អត្តសញ្ញាណនៃម្ចាស់ហ៊ុន, និង អ្នកទទួល ឬ អ្នកកាន់អាជ្ញាបណ្ណដទៃដែលមានភាគហ៊ុនក្នុងក្រុមហ៊ុនកំពុងស្នើសុំអាជ្ញាបណ្ណ ។
- ***<u>ព័ត៌មានប្រតិបត្តិការទូរគមនាគមន៍បច្ចុប្បន្ន (ករណីអ្នកស្នើកំពុងកាន់កាប់អាជ្ញាបណ្ណផ្សេង)</u>៖*** ប្រភេទអាជ្ញាបណ្ណ, លេខអាជ្ញាបណ្ណ, កាលបរិច្ឆេទអាជ្ញាបណ្ណ, កាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាបណ្ណ, បណ្តាញនិង/ឬសេវាដែលផ្តល់ក្រោមវិសាលភាពនៃអាជ្ញាបណ្ណបច្ចុប្បន្ន ។
- ***<u>ព័ត៌មានសេវាត្រូវផ្តល់</u>៖*** រូបសណ្ឋានបណ្តាញ, បច្ចេកវិទ្យាដែលត្រូវប្រើប្រាស់, ប្រភេទសេវាទូរគមនាគមន៍, យុទ្ធសាស្ត្រធុរកិច្ច កាលបរិច្ឆេទដែលគ្រោងចាប់ផ្តើមប្រតិបត្តិការ, ខេត្ត/ក្រុងដែលគ្រោងប្រតិបត្តិការសេវាក្នុងរយៈពេល ៥ ឆ្នាំ, និង អតិថិជនគ្រោងទុក ។

**ឃ) គំនូសបំព្រួញនៃចរន្តពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍**

- ***អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា និង អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់៖***



- អាជ្ញាបណ្ណសេវាទូរគមនាគមន៍



**ឧបសម្ព័ន្ធ ៥ - បញ្ជីនៃហេដ្ឋារចនាសម្ព័ន្ធនិងសេវាដែលត្រូវមានការអនុញ្ញាត ស្របតាមប្រភេទនៃអាជ្ញាបណ្ណ**

ក ) ***អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា*** អនុញ្ញាតឱ្យអ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណៈ

១ ) ស្ថាបនា ថែទាំ និងប្រតិបត្តិការបណ្តាញហេដ្ឋារចនាសម្ព័ន្ធ ដោយឈរលើ មូលដ្ឋានបច្ចេកវិទ្យាអព្យាក្រឹត្យ។

២ ) ជួលទាំងស្រុង ឬ មួយផ្នែកនៃចំណុះបណ្តាញរបស់អ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណ ឱ្យទៅអ្នកកាន់ ឬទទួលអាជ្ញាបណ្ណសេវា ។

៣ ) ផ្តល់សេវាទូរគមនាគមន៍សាធារណៈ ឬ ឯកជនជាលក្ខណៈក្នុងស្រុក ឬ អន្តរជាតិ ដូចរៀបរាប់ខាងក្រោម ឱ្យទៅសាធារណជន និង/ឬអ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណសេវាដទៃ ។

ជាទូទៅ អាជ្ញាបណ្ណនេះត្រូវការសិទ្ធិប្រើប្រាស់វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ និង លេខទូរគមនាគមន៍ ។ វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុថ្មីដែលមាន អាចដាក់ឱ្យដេញថ្លៃ ។ ប្រតិបត្តិការដែលបានអនុញ្ញាតដោយអាជ្ញាបណ្ណនេះរួមមាន ការស្ថាបនា ថែទាំ ប្រតិបត្តិការ និងផ្តល់សេវាទូរគមនាគមន៍ តាមរយៈ៖

១ ) ហេដ្ឋារចនាសម្ព័ន្ធបណ្តាញបញ្ជូននៅលើគោកសម្រាប់ទូរស័ព្ទអចល័ត និងស្ថានីយមូលដ្ឋានទូរស័ព្ទចល័ត,

២ ) ហេដ្ឋារចនាសម្ព័ន្ធបណ្តាញបញ្ជូនវិទ្យុនៅលើគោក,

៣ ) ហេដ្ឋារចនាសម្ព័ន្ធសេវាមាត់ច្រកអន្តរជាតិ,

៤ ) ស្ថានីយឡើងគោកខ្សែកាប្លិ៍ក្រោមបាតសមុទ្រ (អាស្រ័យលក្ខខណ្ឌចំនួននៃការផ្តល់អាជ្ញាបណ្ណ),

៥ ) ហេដ្ឋារចនាសម្ព័ន្ធបង្ហោះផ្កាយរណប,

៦ ) ហេដ្ឋារចនាសម្ព័ន្ធស្ថានីយផ្កាយរណបលើដី (Satellite Earth Station Facilities)

៧ ) ហេដ្ឋារចនាសម្ព័ន្ធផ្កាយរណបដទៃ ដែលស្ថិតនៅក្នុងប្រទេស សម្រាប់ការបញ្ជូនសេវាទូរគមនាគមន៍ ។

សេវាទូរគមនាគមន៍ ដែលអ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ អាចផ្តល់មាន៖

- សេវាបណ្តាញបមាណីទូរគមនាគមន៍សាធារណៈ,

- សេវាទូរគមនាគមន៍ចល័តសាធារណៈ,

- សេវាវិទ្យុ Trunk សាធារណៈ,

- សេវាទិន្នន័យអត់ខ្សែអចល័ត និង ចល័តសាធារណៈ,

- សេវាផ្កាយរណបតភ្ជាប់ចេញ និង ចូល (Downlink និង Uplink),

- សេវាសំឡេងអន្តរជាតិ,

- សេវាផ្តល់ការតភ្ជាប់សេវាអ៊ិនធឺណិត,

- សេវាបមាណីកម្មអ៊ិនធឺណិត (IPX និង DIX ដោយអាស្រ័យលើលក្ខខណ្ឌកំណត់),

- សេវាគ្រប់គ្រងបណ្តាញទិន្នន័យ,

- សេវាផ្កាយរណបសំឡេង ឬ ទិន្នន័យចល័ត,

- សេវាកាតហៅទូរស័ព្ទអន្តរជាតិ (Calling Card),

- សេវាទូរស័ព្ទបង់ប្រាក់សាធារណៈ (Payphone),

- សេវាវិទ្យុគមនាគមន៍សមុទ្រ និង អវកាស (Maritime និង Aeronautical),

- គមនាគមន៍ចល័តសម្រាប់យន្តហោះ,

ខ) **អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់** អនុញ្ញាតឱ្យអ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណ៖

១) ស្ថាបនា ដំឡើង និង ធ្វើប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធបណ្តាញទូរគមនាគមន៍អកម្ម ដោយឈរលើមូលដ្ឋានបច្ចេកវិទ្យាអព្យាក្រឹត្យ និង ជួលហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ឱ្យទៅអ្នកទទួលអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា ឬ អ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណសេវា ។

២) ស្ថាបនា ដំឡើង និង ថែទាំបណ្តាញទូរគមនាគមន៍ ក្នុងគោលបំណងផ្តល់សេវាទូរគមនាគមន៍ផ្ទាល់ខ្លួន និង ពុំត្រូវលក់ ឬ ជួល ឬ តភ្ជាប់ជាមួយបណ្តាញបមាណីទូរស័ព្ទសាធារណៈឡើយ ។

អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់អនុញ្ញាតឱ្យធ្វើប្រតិបត្តិការទាក់ទងនឹងការដំឡើង និង ថែទាំលើហេដ្ឋារចនាសម្ព័ន្ធអកម្មគ្រប់ប្រភេទ សម្រាប់អ្នកទទួលអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ និងសេវា ដូចខាងក្រោម៖

- បង្គោលអង់តែន Tower,

- បង្គោល Mast,

- បំពង់ Duct,
- រណ្ដៅ Trench,
- សសរ Pole,
- ខ្សែកាប្លិ៍អុបទិក Dark Fiber,
- គ្រឿងសម្ភារៈបរិក្ខារវិទ្យុជំនើងសម្រាប់បញ្ជូន ទទួល និងភ្ជាប់ផ្លូវគមនាគមន៍ តែអ្នកទទួលអាជ្ញាបណ្ណមិនត្រូវផ្ដល់សេវាទូរគមនាគមន៍ (សំឡេង និង ទិន្នន័យ) ឱ្យទៅសាធារណជនឡើយ ។

អ្នកទទួលអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ មិនចាំបាច់ស្នើសុំអាជ្ញាបណ្ណសេវាឡើយ ប្រសិនបើអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណជួលជាវសេវាទូរគមនាគមន៍ឯកជនពីអ្នកកាន់ ឬ អ្នកទទួលអាជ្ញាបណ្ណស្របច្បាប់ផ្សេងទៀត សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ។

គ ) **អាជ្ញាបណ្ណសេវា**

ដោយឈរលើមូលដ្ឋានបច្ចេកវិទ្យានិងសេវាអព្យាក្រឹត្យ អ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណសេវាមានសិទ្ធិជួលចំណុះល្បឿននៃបណ្ដាញបញ្ជូនទិន្នន័យដោយផ្ទាល់ពីអ្នកទទួលអាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវា និង/ឬ អាជ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធនិងសេវាមានដែនកំណត់ ដើម្បីផ្ដល់សេវាទូរគមនាគមន៍សាធារណៈឱ្យទៅអ្នកប្រើប្រាស់ និង/ឬ អ្នកទទួលអាជ្ញាបណ្ណផ្សេងទៀត ឬ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួននៅក្នុងប្រទេស ។

អ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណសេវា ៖

- ពុំត្រូវស្ថាបនា ថែទាំ និង ធ្វើប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធនិង បណ្ដាញទូរគមនាគមន៍ទេ លើកលែងតែ Switches, Routers និង ឧបករណ៍ដំណើរការចាំបាច់សម្រាប់ផ្ដល់សេវាដែលបានទទួលអនុញ្ញាត ។
- មិនត្រូវផ្ដល់សេវាទូរគមនាគមន៍ ដែលត្រូវការលេខទូរស័ព្ទ លើកលែងការធ្វើប្រតិបត្តិការសេវា VoIP ឬ ធនធានវិសាលគមន៍ប្រេកង់ស៍វិទ្យុដែលត្រូវផ្ដល់ដោយ ន.ទ.ក. ឡើយ លើកលែងតែមានការកំណត់ដោយបទប្បញ្ញត្តិផ្សេងទៀត ។
- មានសិទ្ធិប្រើប្រាស់ធនធានវិសាលគមន៍ប្រេកង់ស៍វិទ្យុដែលទទួលការលើកលែងអាជ្ញាបណ្ណ (Unlicensed Frequency) ។

អ្នកកាន់ ឬអ្នកទទួលអាជ្ញាបណ្ណសេវាមានសិទ្ធិធ្វើប្រតិបត្តិការ និង ផ្ដល់សេវាទូរគមនាគមន៍

ដូចខាងក្រោម៖

- សេវាទូរស័ព្ទបង់ប្រាក់សាធារណៈ (Payphone),
- សេវាលក់ដុំ ដូចជាការជួលជាវចំណុះល្បឿនបណ្ដាញបញ្ជូននិងសេវាមាត់ច្រកអន្តរជាតិ ហើយលក់បន្តឱ្យទៅអ្នកប្រើប្រាស់ ឬ អ្នកទទួលអាជ្ញាបណ្ណផ្សេងទៀត,
- សេវាសំឡេងតាមរយៈពិធីការអ៊ិនធឺណិត VoIP,
- សេវាអ្នកផ្ដល់សេវាអ៊ិនធឺណិត ISP (អាស្រ័យលើលក្ខខណ្ឌកំណត់ស្ដីពីបណ្ដាញឆ្លងដែនអន្តរជាតិ),
- សេវា Data Center សាធារណៈ រួមទាំងសេវា Cloud Computing,
- សេវា Messaging រួមបញ្ចូលទាំងសេវាមាត់ច្រកផ្សាយ SMS,
- សេវា Toll-Free,
- សេវា Private Line សំឡេង និង ទិន្នន័យ,
- សេវាតម្លៃបន្ថែម (VAS),
- សេវា VSAT,
- សេវា និង កម្មវិធី OTT (អាស្រ័យលើបទប្បញ្ញត្តិនាពេលអនាគត) ។/